ក្រសួងអប់រំ យុវជន និងកីឡា

**Ministry of Education, Youth and sport**

វិទ្យាស្ថានជាតិអប់រំ

**National Institute of Education**

# និក្ខេបបទ

# កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សា

# ករណីសិក្សា៖ ខេត្តតាកែវ

## The Frequency of Helping Slow Learners at Primary School

## Case Study: Takeo Province


ដោយ/By

**ជា តត**

CHEA TORT


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩


ឧបត្ថម្ភដោយ ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by: Cambodia International Education Support Foundation (CIESF)

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

# និក្ខេបបទ

# កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សា

## The Frequency of Helping Slow Learners at Primary School


ដោយ/By

**ជា តត**

CHEA TORT


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩

សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត សិត សេង

សាស្ត្រាចារ្យដឹកនាំរង ៖ លឹម វ៉ាន់


ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦២៩ **អយក.** ខល

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំ | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមអះអាងថា និក្ខេបបទស្រាវជ្រាវស្តីអំពី " **កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សា**" សម្រាប់បំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះគឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង ហើយស្នាដៃនេះមិនទាន់ត្រូវបានប្រើប្រាស់ក្នុងការបំពេញលក្ខខណ្ឌសិក្សានៅវិទ្យាស្ថាននេះ នៅវិទ្យាស្ថានផ្សេង ឬនៅសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារណាមួយដែលត្រូវបានប្រើប្រាស់នៅក្នុងស្នាដៃស្រាវជ្រាវនេះដោយពុំមានការអនុញ្ញាត ឬមិនបានចុះក្នុងបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះពិតជាស្នាដៃរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃអង្គារ១៤កើត ខែមិគសិរ ឆ្នាំកុរឯកស័កព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ជា តត**

# លិខិតបញ្ជាក់

បណ្ឌិត **សិត សេង** ជាសាស្ត្រាចារ្យដឹកនាំ

លោក **លឹម វ៉ាន់** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

**លោក ជា តត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទសិក្សាស្រាវជ្រាវ"**កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សា**" ប្រាកដមែន។

ថ្ងៃអង្គារ១៤កើតខែមិគសិរ ឆ្នាំកុរឯកស័កព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

.................................. .....................................

បណ្ឌិត សិត សេង លោក លឹម វ៉ាន់

នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងមូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា(CIESF) ដែលបានរៀបចំផ្តល់អាហារូបករណ៍ដល់រូបខ្ញុំបាទ ដើម្បីបានចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះ។

សូមគោរពថ្លែងអំណរគុណដល់ឯកឧត្តមនាយក លោកនាយករង លោក លោកស្រី ដែលជាសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំទាំងអស់ ដែលបានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលរូបខ្ញុំបាទរហូតបានជោគជ័យ។ ជាពិសេសខ្ញុំបាទសូមថ្លែងអំណរគុណដល់លោក**បណ្ឌិត សិត សេង** ជាសាស្ត្រាចារ្យដឹកនាំ និង**លោក លឹម វ៉ាន់** ជាសាស្ត្រាចារ្យដឹកនាំរងដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ពន្យល់ និងកែសម្រួលទៅលើនិក្ខេបបទនេះតាំងពីដើមរហូតដល់ចប់។

ខ្ញុំបាទសូមថ្លែងអណរគុណដល់លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុងដូនកែវ លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកសំរោង លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកបាទី និងលោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកត្រាំកក់ដែលបានសម្របសម្រួល និងអនុញ្ញាតឱ្យខ្ញុំបាទចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅ។ ជាមួយគ្នានេះផងដែរ ក៏សូមថ្លែងអណរគុណដល់លោកនាយក លោកគ្រូ អ្នកគ្រូក្នុងសាលាគោលដៅទាំងប្រាំបី និងអាណាព្យាបាលសិស្សដែលបានចំណាយពេលវេលា និងកិច្ចសហការក្នុងការផ្តល់ព័ត៌មានដល់រូបខ្ញុំបាទដើម្បីឱ្យការចុះប្រមូលទិន្នន័យ និងការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរចំពោះលោក លោកស្រី លោកគ្រូ អ្នកគ្រូទាំងអស់ សូមមានសុខភាពល្អ កម្លាំងកាយមាំមួន ជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ

# មូលន័យសង្ខេប


សិស្សរៀនយឺតជាប្រភេទសិស្សដែលងាយប្រឈមនឹងការត្រួតថ្នាក់ និងការបោះបង់ការសិក្សាប្រសិនបើពួកគេត្រូវបានគេទុកចោលដោយមិនបានយកចិត្តទុកដាក់ជាពិសេស ក្នុងការជួយទៅដល់ការសិក្សារៀនសូត្រប្រចាំថ្ងៃរបស់ពួកគេ។ ហេតុដូចនេះហើយ ទើបតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដូចជាសាលារៀន សហគមន៍ និងអាណាព្យាបាលជាដើម ក្នុងការជួយពួកគេឱ្យទទួលបាននូវការអប់រំមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងស្វែងរកឱ្យឃើញនូវសកម្មភាពល្អៗដែលកំពុងត្រូវបានអនុវត្ត និងកិច្ចគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធព្រមទាំងបញ្ហាប្រឈមនានាក្នុងការជួយសិស្សរៀនយឺតនៅកម្រិតបឋមសិក្សា។

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយចុះប្រមូលទិន្នន័យដោយផ្ទាល់តាមរយៈការបំពេញកម្រងសំណួរពីគណៈនាយកសាលា គ្រូប្រចាំថ្នាក់ និងអាណាព្យាបាលសិស្សរៀនយឺត។

ឆ្លងតាមការវិភាគទៅលើទិន្នន័យដែលប្រមូលបាននេះ លទ្ធផលបានបង្ហាញថាមានសកម្មភាពល្អៗជាច្រើនដែលសាលារៀនកំពុងអនុវត្តទាំងនៅក្នុងក្រុង និងក្រៅក្រុង ព្រមទាំងកិច្ចគាំទ្រពីភាគីពាក់ព័ន្ធក្នុងការជួយសិស្សរៀនយឺតនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ បញ្ហាប្រឈមមួយចំនួនដែលបង្កការរាំងស្ទះដល់កិច្ចការអនុវត្តការជួយសិស្សរៀនយឺតនេះនៅតែមាន ដូចជាការមិនសូវយកចិត្តទុកដាក់ក្នុងការជួយបង្រៀនកូនបន្ថែមនៅផ្ទះរបស់ឪពុកម្ដាយ ឬអាណាព្យាបាល ការទំនាក់ទំនងរវាងសាលារៀន និងអាណាព្យាបាលសិស្សនៅមានកម្រិត។

ជារួម ការស្រាវជ្រាវនេះបង្ហាញពីកម្រិតនៃការយកចិត្តទុកដាក់របស់សាលារៀនទៅលើការជួយសិស្សរៀនយឺត កម្រិតនៃកិច្ចសហការគ្នារវាងសាលារៀន និងឪពុកម្ដាយ ឬអាណាព្យាបាលសិស្ស ព្រមទាំងបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ការជួយពួកគេឱ្យមានលទ្ធភាពចាប់បាននូវខ្លឹមសារមេរៀនដូចសិស្សដទៃទៀត។

## Abstract

Slow learners are the type of students who are at risk of repetition and dropout if they don't get any especial attention in assisting with their daily learning. It is, therefore, needed the participation of all stakeholders, such as schools, community and parents in helping them to achieve the effective education.

The research aims to find out best practice which is implementing at school and advocacy from all stakeholders as well as the challenges of helping slow learners at primary schools.

This research is conducted through direct data collection by completing questionnaires from principals, teachers and slow learners' parents.

From the analysis of the data collected, the result show that there is much best practice that schools are implementing both in the town and out of town, as well as the support of stakeholders in helping slow learners effectively. However, some challenges that may hinder the implementation of assisting slow learners such as parents pay less attention in tutoring their children at home, low communication between parents and school still exist.

In short, this research focus on the level of helping slow learners of school principals and teachers, the level of the school-parent collaboration, and the challenges that prevent them from being able to afford the contents of the lessons just like the other students.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........................................ i

លិខិតបញ្ជាក់ ........................................ ii

សេចក្តីថ្លែងអំណរគុណ ........................................ iii

មូលន័យសង្ខេប ........................................ iv

មាតិកា

........................................ vi

បញ្ជីរូបភាព ........................................ x

ជំពូកទី១៖ សេចក្តីផ្តើម ........................................ 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ 3

១.៣. គោលបំណងនៃការស្រាវជ្រាវ ........................................ 5

១.៤. សំណួរស្រាវជ្រាវ ........................................ 5

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ 5

១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាជ្រាវ ........................................ 6

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 6

ជំពូកទី២៖ រំឭកទ្រឹស្តី ........................................ 8

២.១ និយមន័យពាក្យគន្លឹះ ........................................ 9

២.២ លក្ខណៈសិស្សរៀនយឺត ........................................ 10

២.៣ មូលហេតុដែលនាំឱ្យសិស្សរៀនយឺត ........................................ 11

២.៤ តួនាទី និងភារកិច្ចរបស់នាយកសាលា ប្រធានក្រុមបច្ចេកទេស ........................................

និងគ្រូប្រចាំថ្នាក់ក្នុងការជួយសិស្សរៀនយឺត ........................................ 13

២.៤.១.នាយកសាលា ........................................ 13

២.៤.២. ប្រធានក្រុមបច្ចេកទេស ........................................ 14

២.៤.៣. គ្រូប្រចាំថ្នាក់ ......... 15
២.៥.ការជួយកូនរៀនយឺតពីសំណាក់ឪពុកម្តាយ រឺអាណាព្យាបាល ......... 16
២.៦. សកម្មភាពជួយសិស្សរៀនយឺតស្របពេលលើមុខវិជ្ជាភាសាខ្មែរ ......... 17
ក. សមត្ថភាពនិយាយ ......... 17
ខ. សមត្ថភាពស្តាប់ ......... 18
ឃ. សមត្ថភាពសរសេរ ......... 20
២.៧. សកម្មភាពជួយសិស្សរៀនយឺតស្របពេលលើមុខវិជ្ជាគណិតវិទ្យា ......... 21
៤.៧. វិធីសាស្ត្រជួយសិស្សរៀនយឺតក្នុងពេលកំពុងបង្រៀន ......... 22
ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ......... 24
៣.១. ការជ្រើសរើសសំណាក ......... 24
៣. ២. ឧបករណ៍ស្រាវជ្រាវ ......... 24
៣.២.១. កម្រងសំណួរសម្រាប់គណៈនាយកសាលា ......... 24
៣.២.២. កម្រងសំណួរសម្រាប់គ្រូប្រចាំថ្នាក់ ......... 25
៣.២.៣. កម្រងសំណួរសម្រាប់ឪពុកម្តាយ ឬអាណាព្យាបាលសិស្សរៀនយឺត ......... 25
៣.៤. ដំណើរការប្រមូលទិន្នន័យ ......... 26
៣.៥. ការវិភាគទិន្នន័យ ......... 26
៣.៦. ក្រមសីលធម៌ក្នុងការស្រាវជ្រាវ ......... 27
ជំពូកទី ៤៖ ការវិភាគ និងបំណកស្រាយ ......... 28
៤.១. គុណវុឌ្ឍិនាយកសាលា - គ្រូប្រចាំថ្នាក់ ......... 29
៤.២. មុខរបរអាណាព្យាបាលសិស្សរៀនយឺត ......... 30
៤.៣. ស្ថិតិសិស្សរៀនយឺតតាមថ្នាក់ ......... 31
៤.៤. មុខវិជ្ជាដែលសិស្សរៀនយឺតជួបការលំបាក ......... 32
៤.៥. ការរៀបចំសកម្មភាពជួយសិស្សរៀនយឺត ......... 33
ក. សកម្មភាពសិស្សជួយសិស្ស (ខ្លាំងជួយខ្សោយ) ......... 33

ខ. ការរៀបចំកន្លែងអង្គុយ ....................................................................................34
គ. ការងារក្រុម ....................................................................................34
ឃ. ការហៅសិស្សរៀនឡើងឆ្លើយសំនួរ និងឡើងក្ដារខៀន ....................................................................................35
៤.៦. ការដាក់ និងការកែកិច្ចការផ្ទះ ....................................................................................35
៤.៧. ការជួយបង្រៀនកូនបន្ថែមនៅផ្ទះ ....................................................................................36
៤.៨. ការទំនាក់ទំនងរវាងសាលារៀន និងអាណាព្យាបាលសិស្សរៀនយឺត ....................................................................................38
៤.៨.១. ការជួបប្រជុំរវាងនាយកសាលា និងអាណាព្យាបាលសិស្សរៀនយឺត ....................................................................................38
៤.៨.៣. ការបញ្ជូន និងការទទួលសៀវភៅតាមដានការសិក្សា ....................................................................................40
ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ ....................................................................................44
៥.១. សន្និដ្ឋាន ....................................................................................44
៥.២. សំណូមពរ ....................................................................................45
ឯកសារយោង ....................................................................................47
ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ....................................................................................50
ឧបសម្ព័ន្ធទី២៖ តារាងតម្លៃស្ថិតិ ....................................................................................53
តារាងទី១៖ គុណវុឌ្ឍិគណៈនាយកសាលា- គ្រូប្រចាំថ្នាក់ ....................................................................................53
តារាងទី២៖ ស្ថិតិសិស្សរៀនយឺតតាមថ្នាក់ ....................................................................................53
តារាងទី៣៖ មុខវិជ្ជាដែលសិស្សរៀនយឺតជួបការលំបាក ....................................................................................53
តារាងទី៤៖ ការរៀបចំសកម្មភាពសិស្សខ្លាំងជួយសិស្សខ្សោយ ....................................................................................54
តារាងទី៥៖ ការងារក្រុម ....................................................................................54
តារាងទី៦៖ ការហៅសិស្សរៀនយឺតឡើងឆ្លើយសំណួរ និងឡើងក្ដារខៀន ....................................................................................55
តារាងទី៧៖ ការដាក់ និងការកែកិច្ចការផ្ទះ ....................................................................................55
តារាងទី៨៖ ការជួយបង្រៀនកូនបន្ថែមនៅផ្ទះ ....................................................................................55
តារាងទី៩៖ ការជួបប្រជុំរវាងនាយកសលា និងអាណាព្យាបាលសិស្សរៀនយឺត ....................................................................................56

តារាងទី១០៖ ការផ្តល់ និងការទទួលព័ត៌មានអំពីការសិក្សារបស់សិស្សរៀនយឺតរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាល ....................................................................................... 56
តារាងទី១១៖ ការបញ្ជូន និងទទួលសៀវភៅតាមដានការសិក្សា..................................... 57
ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរ ......................................................................................... 59
ឧបសម្ព័ន្ធទី ៤៖ ............................................................................................................... 66
១-គណៈកម្មការមេប្រយោគ ............................................................................................ 66
២-គណៈកម្មការការពារនិក្ខេបបទ................................................................................ 67
៣-គណៈកម្មការកណ្តាល ................................................................................................ 68

# បញ្ជីរូបភាព

រូបទី១៖ គុណវុឌ្ឍិនាយក-គ្រូប្រចាំថ្នាក់ ........................................................... ៣០

រូបទី២៖ មុខរបរអាណាព្យាបាលសិស្សរៀនយឺត............................................... ៣២

រូបទី៣៖ ស្ថិតិសិស្សរៀនយឺតតាមថ្នាក់ ........................................................... ៣៣

រូបទី៤៖ មុខវិជ្ជាដែលសិស្សរៀនយឺតជួបការលំបាក ......................................... ៣៤

រូបទី៥៖ ការរៀបចំសកម្មភាពជួយសិស្សរៀនយឺត ............................................ ៣៥

រូបទី៦៖ ការដាក់ និងការកែកិច្ចការផ្ទះ ............................................................ ៣៩

រូបទី៧៖ ការជួយបង្រៀនកូនបន្ថែមនៅផ្ទះរបស់អាណាព្យាបាល .......................... ៤០

រូបទី៨៖ ការប្រជុំពិភាក្សារវាងនាយកសាលា និងអាណាព្យាបាលសិស្សរៀនយឺត..៤២

រូបទី៩៖ ការផ្តល់ព័ត៌មានរបស់គ្រូប្រចាំថ្នាក់ទៅអាណាព្យាបាលសិស្សរៀនយឺត.... ៤៤

រូបទី១០៖ ការបញ្ជូន និងទទួលសៀវភៅតាមដានការសិក្សា ............................... ៤៦

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការអប់រំគឺជាច្រកដ៏សំខាន់ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយសក្តានុពល ដែលមនុស្សជាតិគ្រប់រូបនៅលើពិភពលោកត្រូវការមិនអាចខ្វះបាន ដោយសារវាបានផលិតនូវធនធានមនុស្សមិនចេះរីងស្ងួត ដែលធ្វើឱ្យមនុស្សជាតិរស់នៅក្នុងភាពថ្លៃថ្នូរ។ កុមារគឺជាទំពាំងស្នងឫស្សី និងជាធនធានដ៏សំខាន់បំផុតសម្រាប់ស្នងមតិកដ៏មានតម្លៃនៃជាតិសាសន៍ទាំងមូល។ សាលារៀន សហគមន៍ និងមាតាបិតា អាណាព្យាបាលសិស្សដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាអប់រំ ដើម្បីប្រែក្លាយពួកគេជាពលរដ្ឋពេញលេញប្រកបដោយសមត្ថភាពចំណេះដឹង ជំនាញវិជ្ជាជីវៈ ការច្នៃប្រតិដ្ឋខ្ពស់ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពល្អ និងកាយសម្បទាមាំមួន ។

នៅលើលោកនេះ មិនថាជាតិសាសន៍ណានោះទេគឺគេតែងចាត់ទុកការអប់រំគឺជាគន្លឹះសំខាន់បំផុត ព្រោះមានតែការអប់រំទេដែលធ្វើឱ្យជាតិសាសន៍គេមានការរីកចម្រើន។ ការអប់រំបានធ្វើឱ្យមនុស្សរកឃើញនូវអ្វីដែលថ្មី។ ការអប់រំល្អនឹងធ្វើឱ្យមនុស្សរស់នៅក្នុងសន្តិភាព សេរីភាព សេចក្តីថ្លៃថ្នូរ ចាកផុតពីការជិះជាន់កេងប្រវ័ញ្ច ការរើសអើង និងធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍប្រកបដោយចីរភាព។

ជាមួយគ្នានេះដែរ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភា ក៏បានផ្តល់អាទិភាពលើវិស័យអប់រំដោយបានលើកឡើងពីការអភិវឌ្ឍធនធានមនុស្សនៅក្នុងមុំទីមួយរបស់ខ្លួន គឺសំដៅលើ ១) ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង៤) ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម*(យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤, 2018)*។ នេះសបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើគុណភាពអប់រំ ដើម្បីធានាបាននូវការអភិវឌ្ឍជាតិ និងការប្រកួតប្រជែងខ្ពស់នៅក្នុងសម័យសាកលភាវូបនីយកម្មទំនើបនេះ។

ដើម្បីសម្រេចបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់ និងឱ្យស្របទៅតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយអប់រំសំខាន់ៗបីគឺ៖

- **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

- **គោលនយោបាយទី២៖** លើកកម្ពស់គុណភាព និងភាពឆ្លើយតប។
- **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។(**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨**)

នៅឆ្នាំ២០១៦ ក្រសួងអប់រំបានធ្វើការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងបានកែសម្រួលគោលនយោបាយអប់រំមកត្រឹមពីរវិញ ក្នុងគោលបំណងឱ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ស្ដីពីការអប់រំនៅកម្ពុជាដែលមានខ្លឹមសារដូចខាងក្រោម៖

- **គោលនយោបាយទី១៖** ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។
- **គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។(**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣)**

ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងតាមរយៈការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សាឱ្យបានចូលរៀន ការសាងសង់អគារសិក្សា ការផ្ដល់គ្រូបង្រៀន ការផ្ដល់ថវិកាដំណើរការសាលារៀន ការផ្ដល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេសសិស្សនារីជាដើម បានបង្កលក្ខណៈឱ្យកុមារមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំ ដោយចំនួនសិស្សនៅបឋមសិក្សាក្នុងឆ្នាំសិក្សា២០១៧-២០១៨ មាន ២,០២៨,៦៩៤នាក់ ស្រី៩៧៥,៥៦៣នាក់ ដែលក្នុងនោះកុមារចុះឈ្មោះចូលរៀនថ្នាក់ទី១ថ្មីមានចំនួន ៣៤០,៤៧៩នាក់ អាយុ៦ឆ្នាំមាន២៦៩,៦៧៤នាក់ (**អ.យ.ក. ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំ២០១៧-២០១៨**)។

បើទោះជាមានកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជាព្រមទាំងក្រសួងអប់រំ យុវជន និងកីឡាក្នុងការធ្វើកំណែទម្រង់លើវិស័យអប់រំយ៉ាងនេះក្ដី ក៏លទ្ធផលនៃការអប់រំនៅមិនទាន់សម្រេចតាមការចង់បាន១០០%ដែរ ជាពិសេស សិស្សរៀនយឺតនៅតែស្ថិតក្នុងបញ្ហាប្រឈម ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសពីសំណាក់គ្រូបង្រៀន គណៈគ្រប់គ្រងសាលា មាតាបិតា និងអាណាព្យាបាលជាដើម។ ជាក់ស្ដែងក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះ ចំនួនសិស្សត្រួតថ្នាក់នៅទូទាំងប្រទេសតាមកម្រិតថ្នាក់នីមួយៗនៅបឋមសិក្សាគឺ៖ ថ្នាក់ទី១៖ ៤៦,៣៨៥នាក់ ថ្នាក់ទី២៖ ៣០,៣៤៣ នាក់ ថ្នាក់ទី៣៖ ២២,០៤៣ នាក់ ថ្នាក់ទី៤៖ ១៥,៦០៥នាក់ ថ្នាក់ទី៥៖១០,២៤៩នាក់ ថ្នាក់ទី៦៖ ៧,១៣៨នាក់។ (**ក្រសួងអប់រំ យុវជន និងកីឡា, ស្ថិតិ និងសូចនាករអប់រំសាធារណៈ ២០១៧-២០១៨**)។

ការអប់រំចំពោះកុមារជារឿងចាំបាច់បំផុត ហើយការជួយជាពិសេសដល់សិស្សដែលរៀនយឺតវារឹតតែជារឿងសំខាន់ថែមទៀតដើម្បីទប់ស្កាត់អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា ដែលជាជំនួយឱ្យពួកគេអាចមានលទ្ធភាពបន្តការសិក្សាទៅថ្នាក់លើៗជាបន្តទៀត។ ហេតុនេះ វាទាមទារឱ្យមានការយកចិត្តទុកដាក់ព្យាយាម និងអំណត់ជាទីបំផុតពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសគឺគណៈនាយកសាលា ប្រធានក្រុមបច្ចេកទេស គ្រូទទួលបន្ទុកថ្នាក់ និងអាណាព្យាបាលដែលជាអ្នកនៅផ្ទាល់នឹងសិស្សជាប្រចាំក្នុងការជួយពួកគេ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការអប់រំនៅបឋមសិក្សាត្រូវបានចាត់ទុកជាអាទិភាពមួយ និងទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា។ ចំនួនសាលាបឋមសិក្សាបានកើនឡើងជាបន្តបន្ទាប់ ក្នុងពេលដែលសាលារៀនមិនគ្រប់កម្រិត និងសាលារៀនជួបការលំបាកបានថយចុះរៀងគ្នាពី ៨១៦ និង ១២៩ក្នុងឆ្នាំសិក្សា២០១៣-២០១៤ មក ៥៣២ និង៥៨ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដែលបានធ្វើឱ្យមានភាពប្រសើរឡើងដល់ការធ្វើដំណើរទៅសាលារៀន និងបន្តការសិក្សារបស់សិស្សានុសិស្សនៅបឋមសិក្សា (**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣**)។ កុមារមកពីគ្រួសារក្រីក្រនៅតាមតំបន់ជនបទត្រូវបានទទួលអាហារូបករណ៍ ក្នុងគោលបំណងជួយបង្កើនអត្រាឆ្លងភូមិសិក្សាពីថ្នាក់បឋមសិក្សាទៅអនុវិទ្យាល័យដើម្បីឱ្យសម្រេចបាននូវការធ្វើសាកលកម្មការអប់រំមូលដ្ឋានចំនួនប្រាំបួនឆ្នាំ (**គោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ១៩៩៦**) និងស្របតាមរដ្ឋធម្មនុញ្ញមាត្រា ៦៨ដែលបានចែងថា "រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ"។ (**រដ្ឋធម្មនុញ្ញ, ១៩៩៣**)។

ប៉ុន្តែទោះជាបែបនេះក្តី បញ្ហាសិស្សរៀនយឺតនៅតែជាបញ្ហាប្រឈមក្នុងការបង្រៀន និងរៀននៅកម្រិតបឋមសិក្សា។ ជាក់ស្តែងក្នុងឆ្នាំសិក្សា២០១២-២០១៣ នៅបឋមសិក្សាមានសិស្សសរុបនៅទូទាំងប្រទេស ២,១៧៣,៣៨៤ នាក់ សិស្សត្រួតថ្នាក់ចំនួន១១៤,៣៩១នាក់ ស្មើនឹង ៥,២៦% ខេត្តតាកែវមានសិស្សសរុប១៤១,៤៣៣នាក់ ស្រី៦៤,៧៩០នាក់ សិស្សត្រួតថ្នាក់សរុប ៥៩៣៨នាក់ ស្មើនឹង៤,២០% (**ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២០១២-២០១៣**)។ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ នៅបឋមសិក្សាមានសិស្សសរុបនៅទូទាំងប្រទេស ២,០៧៣,៨១១នាក់ សិស្សត្រួតថ្នាក់មានចំនួន១០៥,៣៥៣នាក់ ស្មើនឹង៥,០៨% ខេត្តតាកែវមានសិស្សសរុបចំនួន ១៣១,១៥៤នាក់ ស្រី៦២,១១២នាក់ សិស្សត្រួតថ្នាក់មានចំនួន៥,២៥២នាក់ ស្មើនឹង៤%(**ស្ថិតិ**

**និងសូចនាករអប់រំ ឆ្នាំ២០១៣-២០១៤**)។ ក្នុងឆ្នាំសិក្សា២០១៤-២០១៥ នៅបឋមសិក្សាមានសិស្សសរុបនៅទូទាំងប្រទេស ២,០១២,១៧៥នាក់ សិស្សត្រួតថ្នាក់មាន១០៦,៣២២នាក់ ស្មើនឹង៥,២៨% ខេត្តតាកែវមានសិស្សសរុបចំនួន១២៦,៣៥១នាក់ ស្រី៦០,២៣៥នាក់ សិស្សត្រួតថ្នាក់មានចំនួន៥,១២១នាក់ ស្មើនឹង៤,០២%(**ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២០១៤-២០១៥**)។ ក្នុងឆ្នាំសិក្សា២០១៥-២០១៦ នៅបឋមសិក្សាមានសិស្សសរុបនៅទូទាំងប្រទេស ២,០១០,៦៧៣នាក់ សិស្សត្រួតថ្នាក់មានចំនួន ១៣៥,៦៧៨នាក់ ស្មើនឹង៦,៧៥% ខេត្តតាកែវមានសិស្សសរុបចំនួន១២៣,២៥៨នាក់ ស្រី៥៨,៩៩៧នាក់ សិស្សត្រួតថ្នាក់មានចំនួន៧,៩០៤នាក់ ស្មើនឹង៦,៤១% (**ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២០១៥-២០១៦**)។ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ នៅបឋមសិក្សាមានសិស្សសរុបនៅទូទាំងប្រទេសចំនួន ២,០២២,០៦១នាក់ សិស្សត្រួតថ្នាក់មានចំនួន១៣៣,៧៩៣នាក់ ស្មើនឹង៦,៦២% ខេត្តតាកែវមានសិស្សសរុបចំនួន១២២,៦២៦នាក់ ស្រី៥៧,៩១១នាក់ សិស្សត្រួតថ្នាក់មានចំនួន៧,៦០៩នាក់ ស្មើនឹង៦,២១%(**ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០១៦-២០១៧**)។ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ នៅបឋមសិក្សាមានសិស្សសរុបនៅទូទាំងប្រទេសចំនួន២,០២៨,៦៩៤នាក់ សិស្សត្រួតថ្នាក់មានចំនួន១៣១,៧៦៣នាក់ ស្មើនឹង៦,៤៩% ខេត្តតាកែវមានសិស្សសរុបចំនួន១១៩,៧០៦នាក់ ស្រី៥៧,១៤១នាក់ សិស្សត្រួតថ្នាក់មានចំនួន៧៦៨០នាក់ ស្មើនឹង៦,៤២% (**ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០១៧-២០១៨**)។ ផ្អែកលើលទ្ធផលនេះឃើញថា ការប្រែប្រួលនៃអត្រាសិស្សរៀនយឺតនៅបឋមសិក្សាក្នុងខេត្តតាកែវនៅតែជាបញ្ហាប្រឈមដែលគ្រប់ភាគីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីឱ្យអត្រានៃការត្រួតថ្នាក់នេះមានការថយចុះជាលំដាប់ និងកាត់បន្ថយការបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាដើម្បីឱ្យពួកគេមានលទ្ធភាពបន្តការសិក្សារហូតបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន។

តាមឯកសាររបស់ Mrs. D. Muppudathi, (2014): Role of teachers on helping slow learners to bring out their hidden skills. បានបង្ហាញថាសិស្សរៀនយឺតមិនមែនជាសិស្សដែលមានពិការភាពផ្នែកសតិបញ្ញាតាមរយៈការកំណត់រោគវិនិច្ឆ័យដែលស្ថិតក្រោមលក្ខខណ្ឌវេជ្ជសាស្ត្រ និងស្ថិតនៅក្នុងចំណាត់ប្រភេទសិស្សដែលត្រូវទទួលការអប់រំពិសេសនោះទេ។ ពួកគេនៅតែអាចមានលទ្ធភាពទទួលយកបាននូវគ្រប់ជំនាញសិក្សាចាំបាច់ទាំងអស់ ប៉ុន្តែស្ថិតនៅក្នុងលំដាប់ក្រោមកម្រិតសិស្សមធ្យម។ ដើម្បីអាចចាប់បានច្បាស់លាស់នូវគ្រប់បញ្ញត្តិសិក្សាទាំងឡាយ ពួកគេត្រូវការពេលវេលាបន្ថែម ការនិយាយសារឡើងវិញច្រើនដង និងធនធានបន្ថែមពីគ្រូ។ ផ្អែកលើន័យនេះ ពួកគេនៅតែមានលទ្ធភាពចាប់យកបាននូវខ្លឹមសារមេ

រៀនថ្មីដូចសិស្សដទៃទៀតដែរក្នុងករណីមានការជួយជ្រោមជ្រែងយកចិត្តទុកដាក់បន្ថែមពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងឪពុកម្ដាយ ឬអាណាព្យាបាលជាដើម។

ដោយសង្កេតឃើញនូវបញ្ហា និងសូចនាករនានាដែលពាក់ព័ន្ធនឹងការសិក្សារបស់កុមារនៅបឋមសិក្សា ជាពិសេសគឺកុមារដែលរៀនយឺតនេះហើយ ទើបប្រធានបទ **កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សា** ត្រូវបានជ្រើសរើសយកមកធ្វើការសិក្សាស្រាវជ្រាវ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងធំៗពីរគឺ៖

- សិក្សាស្វែងយល់អំពីកម្រិតនៃសកម្មភាព និងកិច្ចគាំទ្រនានាដែលភាគីពាក់ព័ន្ធទាំងអស់អនុវត្តក្នុងការជួយសិស្សរៀនយឺតនៅបឋមសិក្សា។
- សិក្សាស្វែងយល់អំពីបញ្ហាប្រឈមនានាដែលបង្កររាំងស្ទះដល់ការជួយសិស្សរៀនយឺតនៅបឋមសិក្សា។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ សំណួរស្រាវជ្រាវពីរត្រូវបានលើកឡើង៖

1) តើមានសកម្មភាព និងកិច្ចគាំទ្រអ្វីខ្លះដែលកំពុងត្រូវបានអនុវត្តដើម្បីជួយសិស្សរៀនយឺតពីគ្រប់ភាគីពាក់ព័ន្ធ?
2) តើបញ្ហាប្រឈមអ្វីខ្លះដែលបង្កការរាំងស្ទះដល់ការជួយសិស្សរៀនយឺត?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ក្នុងការសិក្សាស្វែងយល់ពីស្ថានភាពនៃការជួយសិស្សរៀនយឺតនៅកម្រិតបឋមសិក្សាដោយផ្អែកលើវិធីសាស្ត្រ សកម្មភាព និងកិច្ចគាំទ្រផ្សេងៗដែលត្រូវយកមកអនុវត្តដោយភាគីពាក់ព័ន្ធ ព្រមទាំងបញ្ហាប្រឈមនានាដែលគ្រូបង្រៀនរួមទាំងគណៈគ្រប់គ្រងសាលាកំពុងជួបប្រទះ និងដំណោះស្រាយផ្សេងៗដែលត្រូវយកមកអនុវត្ត ដើម្បីលើកកម្ពស់គុណភាពអប់រំមួយប្រកបដោយប្រសិទ្ធភាព ព្រមទាំងជួយកាត់បន្ថយឱ្យបានជាអតិបរមាអត្រាត្រួតថ្នាក់ និងការបោះបង់ការសិក្សា ដើម្បីធ្វើយ៉ាងណាសម្រេចគោលដៅសម្រាប់ការអប់រំទាំងអស់គ្នា និងផែនការកម្មវិធីកែលម្អគុណភាព និងប្រសិទ្ធភាពបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះទៀតនោះ ការសិក្សានេះបានជួយលើកកម្ពស់ការអនុវត្តគោលនយោបាយអប់រំមួយដែលប្រកបទៅដោយគុណភាព សមធម៌ និងបរិយាបន្ន។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

នៅក្នុងខេត្តតាកែវមានក្រុងមួយ និងស្រុកចំនួនប្រាំបួន ហើយសាលាបឋមសិក្សាដែលស្ថិតក្នុងក្រុង/ស្រុកទាំងនោះមានចំនួន៣៨២។ ការសិក្សាស្រាវជ្រាវលើប្រធានបទ *"កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សា"* នេះគឺធ្វើឡើងនៅក្នុងក្រុងមួយ និងស្រុកចំនួនបីដោយជ្រើសយកសាលាគោលដៅចំនួន៨មកធ្វើសំណាកក្នុងការសិក្សាស្រាវជ្រាវ។ ការជ្រើសយកក្រុងមួយ និងស្រុកគោលដៅទាំងបីមកធ្វើការសិក្សាស្រាវជ្រាវនេះគឺដោយយល់ថា តាមតំបន់នីមួយៗមានរបាយមិនស្មើគ្នារាប់ទាំងចំនួនសិស្ស និងធនធានសម្ភារដែលប្រើប្រាស់ក្នុងសកម្មភាពបង្រៀន និងរៀនជាដើម។ សាលារៀនទាំង៨ដែលត្រូវបានជ្រើសរើសយកមកសិក្សាស្ថិតក្នុងស្រុកត្រាំកក់ ស្រុកបាទី ស្រុកសំរោង និងក្រុងដូនកែវ ដោយបានចែកចេញជាពីរក្រុមគឺសាលាក្នុងក្រុង និងសាលាក្រៅក្រុង។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា

ជំពូកទី១ ៖ សេចក្តីផ្តើម មាន លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី២៖ រំឭកទ្រឹស្តី មាន និយមន័យពាក្យគន្លឹះ លក្ខណៈសិស្សរៀនយឺត មូលហេតុដែលនាំឱ្យសិស្សរៀនយឺត តួនាទី និងភារកិច្ចរបស់នាយកសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូប្រចាំថ្នាក់ក្នុងការជួយសិស្សរៀនយឺត ការជួយកូនៗដែលរៀនយឺតពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាល សកម្មភាពជួយសិស្សរៀនយឺតស្របពេលលើមុខវិជ្ជាភាសាខ្មែរ សកម្មភាពជួយសិស្សរៀនយឺតស្របពេលលើមុខវិជ្ជាគណិតវិទ្យា។

ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ មាន ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរ (កម្រងសំណួរសម្រាប់គណៈនាយកសាលា កម្រងសំណួរសម្រាប់គ្រូប្រចាំថ្នាក់ និងកម្រងសំណួរសម្រាប់ឪពុកម្តាយ ឬអាណាព្យាបាលសិស្សរៀនយឺត)។

ជំពូកទី៤៖ ការបកស្រាយ និងការពិភាក្សាទៅលើគុណវុឌ្ឍិគ្រូ (នាយកសាលា គ្រូប្រចាំថ្នាក់) មុខរបរអាណាព្យាបាលសិស្សរៀនយឺត ស្ថិតិសិស្សរៀនយឺតតាមថ្នាក់ ការរៀបចំសកម្មភាពជួយសិស្សរៀនយឺត ការដាក់ និងកែកិច្ចការផ្ទះ ការជួយបង្រៀនកូនបន្ថែមនៅផ្ទះពីសំណាក់អាណាព្យាបាល ទំនាក់ទំនងរវាងនាយកសាលា និងអាណាព្យាបាលសិស្សរៀនយឺត

ការផ្តល់ព័ត៌មានរបស់គ្រូប្រចាំថ្នាក់ទៅអាណាព្យាបាលសិស្សរៀនយឺត ការបញ្ជូន និងទទួលសៀវភៅតាមដានការសិក្សា បញ្ហាប្រឈម។

ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ ក្នុងជំពូកនេះជាការសង្ខេបលម្អិតឡើងវិញអំពីលទ្ធផលនៃការវិភាគ និងបំណកស្រាយនូវទិន្នន័យដែលបានពីការចុះប្រមូលនៅតាមសាលារៀនគោលដៅទាំង៨។ ក្នុងនោះដែរ ការសន្និដ្ឋាន និងសំណូមពរទៅលើចំណុចមួយចំនួនដែលជាបញ្ហាប្រឈម ឬជាចំណុចខ្វះខាតដែលត្រូវបំពេញបន្ថែមក៏ត្រូវបានលើកយកមកបង្ហាញ។

## ជំពូកទី២៖ រំឭកទ្រឹស្ដី

អាទិភាពទីមួយក្នុងចំណោមអាទិភាពគោលនយោបាយអប់រំធំៗទាំងប្រាំនៃផែនទីបង្ហាញផ្លូវសម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ស្ដីពីការអប់រំនៅកម្ពុជា បានលើកឡើងនូវការគាំពារ និងអភិវឌ្ឍសម្រាប់កុមារគ្រប់រូប ដើម្បីទទួលបាននូវការអប់រំតាំងពីកម្រិតមត្តេយ្យសិក្សា រហូតដល់ការបញ្ចប់ការសិក្សាកម្រិតមូលដ្ឋានដោយឥតបង់ថ្លៃនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយទទួលបានលទ្ធផលសិក្សាប្រកបដោយគុណភាព ប្រសិទ្ធភាព សមធម៌ និងភាពឆ្លើយតប (**អ.យ.ក. 2019, ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០**) ។

ការកសាងប្រព័ន្ធអប់រំមួយដែលប្រកបដោយគុណភាព ប្រសិទ្ធភាព សមធម៌ និងភាពឆ្លើយតបគឺចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្មពីគ្រួសារ សហគមន៍ និងសាលារៀន ក្នុងនោះមានទាំងគណៈនាយកសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូប្រចាំថ្នាក់តែម្ដង ដែលនៅជួបផ្ទាល់នឹងសិស្ស ហើយអាចមានលទ្ធភាពសិក្សាស្វែងយល់ពីតម្រូវការចាំបាច់ ចំណង់ចំណូលចិត្ត និងកត្តាចិត្តសាស្ត្ររបស់សិស្សផ្ទាល់តែម្ដង។

ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធានមនុស្សដែលមានគុណភាព និងគុណតម្លៃដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមមួយមានការរីកចម្រើន ដោយមានមូលដ្ឋានផ្អែកលើចំណេះដឹង និងជំនាញ (**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៥-២០១៨**)។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡាមានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំក្នុងប្រទេសកម្ពុជាឱ្យឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជាជនឱ្យស្របនឹងការរីកចម្រើនក្នុងតំបន់ និងនៅលើពិភពលោក។ ដើម្បីឆ្លើយតបនឹងគោលនយោបាយជាអាទិភាពដូចបានរៀបរាប់ខាងលើនេះ ការជួយដល់សិស្សរៀនយឺតជាកត្តាត្រូវយកចិត្តទុកដាក់ខ្លាំងបំផុតទាំងក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា ទាំងនៅសាលារៀន និងនៅក្នុងគ្រួសារ។ កុមារត្រូវការចាំបាច់នូវពាក្យសម្ដីទន់ភ្លន់ ការលួងលោម ការលើកទឹកចិត្ត និងការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់មាតាបិតា អាណាព្យាបាល និងគ្រូបង្រៀនជាដើម។ ការសម្ដែងអាកប្បកិរិយាដូចរៀបរាប់មកខាងលើនេះចំពោះពួកគេ គឺជាកំលាំងចលករមួយដែលជួយជំរុញពួកគេឱ្យចូលចិត្តសាលារៀន ស្រឡាញ់ការសិក្សា ដែលជាគន្លឹះដ៏សំខាន់ក្នុងការជួយពួកគេឱ្យទទួលបានជោគជ័យ។ (Emily Lisman, 2019)

## ២.១ និយមន័យពាក្យគន្លឹះ

នរណាជាសិស្សរៀនយឺត? មានអ្នកអប់រំជាច្រើនដែលបានសិក្សាស្រាវជ្រាវ និងឱ្យនិយមន័យផ្សេងៗគ្នាទៅលើសិស្សរៀនយឺត។

តាមឯកសាររបស់ Penn Billy Paul, (2016): បានឱ្យនិយមន័យថា "សិស្សរៀនយឺតជាសិស្សទាំងឡាយណាដែលលទ្ធផលនៃការសិក្សារបស់គេមានកម្រិតទាប ដោយកម្រិតនៃភាពឆ្លាតវៃរបស់គេមិនសូវមានភាពសកម្មខ្លាំងដែលមិនអាចទទួលជោគជ័យនៅក្នុងកិច្ចការសាលាតាមរបៀបធម្មតា ។

ចំណែកឯ Julius Bizimungu, (2016): បានពន្យល់ថា សិស្សរៀនយឺតជាសិស្សដែលតាមមិនទាន់នូវអ្វីដែលគ្រូកំពុងបង្រៀន គឺមិនមែនដោយសារតែគេមិនយកចិត្តទុកដាក់នោះទេ តែដោយសារតែប្រាជ្ញារបស់គេមិនអាចចាប់បាននូវខ្លឹមសារមេរៀនទាំងមូល។

Emily Listmann, (2019) បានឱ្យនិយមន័យថា សិស្សរៀនយឺតជាសិស្សដែលល្បឿនសិក្សារបស់គេស្ថិតនៅក្រោយសិស្សផ្សេងទៀតដែលមានអាយុ និងកម្រិតថ្នាក់ដូចគ្នា។ ពួកគេមិនមែនជាសិស្សដែលមានពិការភាពផ្នែកការសិក្សានោះទេ ប៉ុន្តែមុខវិជ្ជាសិក្សាជាបញ្ហាប្រឈមសម្រាប់ពួកគេ។

Susan E. Little, (2000) បានផ្តល់និយមន័យសិស្សរៀនយឺត គឺជាសិស្សទាំងឡាយណាដែលជួបប្រទះនូវការលំបាកជាប្រចាំជាមួយនឹងសកម្មភាពក្នុងថ្នាក់រៀនប្រចាំថ្ងៃ ប៉ុន្តែពិន្ទុរបស់គេមិនមែនទាបរហូតដល់កម្រិតមួយដែលមិនអាចជួយបាននោះទេ។

ទាញការសំយោគរួមចេញពីការឱ្យនិយមន័យខាងលើនេះ យើងអាចនិយាយជារួមថា សិស្សរៀនយឺតគឺជាសិស្សដែលសមត្ថភាពបញ្ញាក្នុងការចាប់យកខ្លឹមសារមេរៀនក្នុងពេលសិក្សាមានសភាពយឺតយ៉ាវ មិនអាចតាមទាន់ឱ្យបានគ្រប់ជ្រុងជ្រោយនូវអ្វីដែលគ្រូកំពុងបង្រៀនដូចសិស្សពូកែ ឬសិស្សមធ្យមនៅក្នុងថ្នាក់តែមួយ។ ប៉ុន្តែមិនមែនមានន័យថាពួកគេរៀនមិនកើតនោះទេ ពួកគេគ្រាន់តែត្រូវការការយកចិត្តទុកដាក់បន្ថែមពីគ្រូ ឪពុកម្តាយ ឬអាណាព្យាបាលដើម្បីអាចមានលទ្ធភាពចាប់បានខ្លឹមសារមេរៀនដូចសិស្សដទៃទៀត។

## ២.២ លក្ខណៈសិស្សរៀនយឺត

Technical Education Quality Improvement Program (TEQIP), (2009) បានកំណត់អត្តសញ្ញាណសិស្សរៀនយឺតថាជាសិស្សទាំងឡាយណាដែលធ្លាក់មធ្យមភាគលើសពីសែសិប ឬហាសិបភាគរយនៃមុខវិជ្ជាសិក្សាប្រចាំឆ្នាំ។ ជាទូទៅពួកគេជាប្រភេទសិស្សដែលអវត្តមានច្រើន។ ចំណែក Mumpuniati (2007) បានកំណត់លក្ខណៈសិស្សរៀនយឺតដោយផ្តោតទៅលើលទ្ធផលនៃពិន្ទុ IQ ក្នុងចន្លោះពី ៧០ ទៅ៨៥។

លោកSteven R. Shaw (2010) បានកំណត់លក្ខណៈរបស់សិស្សរៀនយឺតដូចតទៅ៖

1. កម្រិតបញ្ញា និងការសម្តែងចេញនូវសកម្មភាពសិក្សាមានកម្រិតទាប ប៉ុន្តែមិនដល់កម្រិតត្រូវទទួលការអប់រំពិសេសដោយសារតែពិការភាពផ្នែកការសិក្សា ឬការយល់ដឹងនោះទេ។
2. គេធ្វើបានល្អនៅពេលដែលព័ត៌មានត្រូវបានបង្ហាញក្នុងរូបភាពរូបី។ បញ្ញត្តិ និងការណែនាំបែបអរូបីមានការលំបាកសម្រាប់ពួកគេ។
3. គេមាការលំបាកក្នុងការផ្ទេរ ឬការធ្វើទូទៅកម្មជំនាញ និងចំណេះដឹង។
4. គេត្រូវការការអនុវត្តច្រើនដង និងពេលវេលាយូរជាងសិស្សដទៃទៀតក្នុងថ្នាក់ចំពោះកិច្ចការដូចគ្នា។
5. គេងាយប្រឈមនឹងការបោះបង់ការសិក្សា។

GL. Reddy, R.Ramar, and A. Kusama, (2006) បានពណ៌នាពីលក្ខណៈបួនចំណុចរបស់សិស្សរៀនយឺត៖

1. ពួកគេមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចាប់យកខ្លឹមសារមេរៀនពេញលេញ រួមទាំងមិនអាចសម្រេចបាននូវស្ថានភាពសិក្សា និងការគិតបែបអរូបី មានការលំបាកក្នុងការគិតបែបសាំញ៉ាំ មានការលំបាកក្នុងការដំណើរការអភិវឌ្ឍការធ្វើទូទៅកម្មផ្នែកបញ្ញត្តិ និងទស្សនៈពិសេសលើមុខវិជ្ជាគណិតវិទ្យា និងភាសា។
2. ការចងចាំរបស់ពួកគេមានកម្រិតទាបដោយសារតែស្ថានភាពនៃការត្រៀមបម្រុងប្រយ័ត្នចំពោះព័ត៌មានដែលត្រូវបានបញ្ជូនមកមិនសូវមានសភាពរឹងមាំ ដូច្នេះគេមិនអាចរក្សាទុកព័ត៌មាននោះបានក្នុងរយៈពេលយូរ។
3. ពួកគេមិនអាចផ្ចង់ស្មារតី និងរក្សាបម្រុងប្រយ័ត្នឱ្យបានលើសពី៣០នាទីទេ។

4. ក្នុងការបញ្ចេញគំនិតពួកគេមានការលំបាកក្នុងការស្វែងរកពាក្យ និងរៀបពាក្យនិយាយនៅពេលដែលត្រូវឡើងបង្ហាញព័ត៌មានអ្វីមួយ។

www.foundationosa.org/slow.htm បានបង្ហាញនូវលក្ខណៈ១០ចំណុចរបស់សិស្សរៀនយឺតដូចតទៅ៖

1. សមត្ថភាពទាបជាងកម្រិតថ្នាក់ដែលពួកគេកំពុងរៀន
2. មិនសូវមានសកម្មភាពនៃការប្រាស្រ័យទាក់ទងល្អជាមួយសិស្សដទៃទៀត
3. តាមមិនទាន់នូវការពន្យល់ណែនាំដែលមានលក្ខណៈសាំញ៉ាំ
4. គ្មានគោលដៅសិក្សាច្បាស់លាស់វែងឆ្ងាយ
5. មានយុទ្ធសាស្ត្រក្នុងខ្លួនតិចតួច ឧទាហរណ៍ដូចជាជំនាញក្នុងការរៀបចំ មានការលំបាកក្នុងការផ្លាស់ប្តូរ និងការធ្វើទូទៅកម្មព័ត៌មាន
6. ទទួលបានពិន្ទុទាបជាប្រចាំក្នុងការប្រឡងបញ្ចប់
7. ធ្វើការបានល្អនៅពេលមានសម្ភារឧបទេសអនុវត្តផ្ទាល់ជាជាងគ្រាន់តែស្តាប់គ្រូពន្យល់
8. មិនសូវចេះលើទឹកចិត្តខ្លួនឯង
9. ធ្វើកិច្ចការមានសភាពយឺតយ៉ាវ
10. យឺតយ៉ាវក្នុងការយល់មេរៀន ហើយមុខវិជ្ជាខ្លះទៀតអាចនឹងមិនយល់សោះ។

## ២.៣ មូលហេតុដែលនាំឱ្យសិស្សរៀនយឺត

នៅក្នុងឯកសារស្រាវជ្រាវរបស់លោក A Vasudevan, (2017): Slow learners-Causes, problems and educational programs សិក្សាពីមូលហេតុមួយចំនួនដែលបណ្តាលឱ្យសិស្សរៀនយឺតបានរកឃើញថា៖

1. **កត្តាផ្ទាល់ខ្លួន៖** មានជំងឺរ៉ាំរ៉ៃរយៈពេលយូរ អវត្តមានច្រើន មានបញ្ហាផ្នែករាងកាយដែលមិនបានតាមដាន បុគ្គលិកលក្ខណៈនៃការទទួលចំណេះដឹងមានកម្រិតខ្សោយ (ភាពឆ្លាតវៃមានកម្រិតទាបដោយអាចចាត់ទុកថាជាមនុស្សកម្សោយបញ្ញា)។
2. **បម្រែបម្រួលនៃបរិស្ថាន៖** បរិក្ខារសម្រាប់ការសិក្សានៅផ្ទះមានតិចតួច បរិមាណអាហារដែលមានគុណភាពមានកម្រិតទាប គេងមិនបានគ្រប់គ្រាន់ មិនមានឱកាសគ្រប់គ្រាន់នៅសាលារៀន (ក្នុងថ្នាក់មានសិស្សច្រើន) ការមិនសូវយកចិត្តទុកដាក់ក្នុង

ការបង្រៀនពីគ្រូ ការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូមិនបានគ្រប់គ្រាន់ វិសមត្តិភាពរវាងផ្ទះ និងសាលារៀន។

3. **កត្តាស្មារតី៖** មិនចូលចិត្តគ្រូប្រចាំថ្នាក់របស់ខ្លួន មិនមានទំនុកចិត្តចំពោះខ្លួនឯង និងតម្រូវការចំពោះភាពជោគជ័យ មានភាពខ្មាស់អៀន និងក្តីបារម្ភច្រើនដែលនាំឱ្យការសម្រេចបានមានកម្រិតទាប។
4. **កត្តាគ្រួសារ៖** ឥរិយាបថឪពុកម្តាយដែលមិនសូវឱ្យតម្លៃលើការអប់រំ មិនបានយកចិត្តទុកដាក់តាមដានការសិក្សារបស់កូន និងមិនបានជួយបង្រៀនបន្ថែមនៅផ្ទះជាប្រចាំ ឥរិយាបថអវិជ្ជមានរបស់ឪពុកម្តាយចំពោះសាលារៀនបានបង្កើតឱ្យមានឥរិយាបថស្រដៀងគ្នានេះចំពោះកូន គ្រួសារក្រីក្រមានអំពើហិង្សាជាដើម។

ចំណែកឯ Saral salomi.D និង Dr.A.Meenakshi Sundaram, (2018) រៀបរាប់ពីមូលហេតុដែលនាំឱ្យសិស្សរៀនយឺតដូចតទៅ៖

- **បម្រុងប្រយ័ត្នរយៈពេលខ្លី៖** សិស្សរៀនយឺតមានបម្រុងប្រយ័ត្នខ្លីមិនអាចផ្ចង់អារម្មណ៍បានយូរ។ ការចងចាំមានរយៈពេលខ្លី ឆាប់ភ្លេចនូវអ្វីដែលពួកគេបានរៀនងាយនឹងធុញ និងបាត់ចំណាប់អារម្មណ៍នឹងដំណើរការបង្រៀនរបស់គ្រូ។
- **គំហើញមិនប្រក្រតី៖** កុមារដែលមានគំហើញមិនប្រក្រតីនឹងមិនមានលទ្ធភាពមើលបានច្បាស់ និងមិនអាចចម្លងបានត្រឹមត្រូវនូវអ្វីដែលគ្រូសរសេរនៅលើក្តារខៀន។ វាប៉ះពាល់ទៅដល់ការរីកលូតលាស់ ការអភិវឌ្ឍ លទ្ធភាពក្នុងការបំពេញតួនាទីនៅក្នុងសង្គម ទំនុកចិត្ត និងការជឿជាក់លើខ្លួនឯងដែលអាចឈានទៅដល់ការបាក់ទឹកចិត្ត ហើយប្រសិនបើមិនបានយកចិត្តទុកដាក់ឱ្យបានសមរម្យទេ កុមារនោះអាចនឹងត្រូវបានគេទុកចោលនៅក្នុងម៉ោងរៀន។
- **បញ្ហាសុខភាព និងអវត្តមាន៖** បញ្ហាសុខភាពគឺជាបុព្វហេតុចំបងដែលបណ្តាលឱ្យសិស្សរៀនយឺត។ សុខភាពខ្សោយធ្វើឱ្យរំខានដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។ សិស្សអវត្តមានញឹកញាប់បូកផ្សំនឹងការមិនសូវយកចិត្តទុកដាក់លើការសិក្សារបស់កូនពីសំណាក់ឪពុកម្តាយ ធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើនរបស់កុមារដោយសារតែកិច្ចការសាលាទាំងឡាយមិនបានបំពេញបន្ថែមនៅផ្ទះដែលធ្វើឱ្យកុមារមិនអាចតាមទាន់មិត្តរួមថ្នាក់របស់គេដែលធ្វើឱ្យគេបាត់ទំនុកចិត្តលើខ្លួនឯង។
- **ឪពុកម្តាយ (រវល់ច្រើន មិនចេះអក្សរ ក្រីក្រ)៖** នៅពេលដែលឪពុកម្តាយមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់កូនៗរបស់ពួកគេ កូនអាចនឹងមានអារម្មណ៍បាត់ភាពកក់ក្តៅ

និងដាច់ឆ្ងាយ។ គេមិនអាចបរិយាយបញ្ហា ឬការលំបាកទាំងឡាយដែលជួបប្រទះនៅសាលាជាមួយឪពុកម្តាយ ពួកគេត្រូវរក្សាទុកនូវអ្វីៗទាំងអស់នៅក្នុងចិត្តតែម្នាក់ឯង ហើយក្លាយទៅជាការស្អប់ចំពោះសាលារៀន និងការអប់រំ។ ឪពុកម្តាយមិនចេះអក្សរ មិនមានទស្សនៈអំពីការអប់រំ មិនខ្វល់ខ្វាយអំពីការសិក្សារបស់កូន។ ឪពុកម្តាយដែលរវល់ ឪពុកម្តាយក្រីក្រចេញទៅធ្វើការតាំងពីព្រឹកព្រលឹម ហើយត្រឡប់មកផ្ទះវិញនៅក្បាលព្រលប់មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសាកសួរអំពីការសិក្សារបស់កូន ឬបញ្ហារបស់ពួកគេដែលធ្វើឱ្យដំណើរការសិក្សារបស់គេលំបាកក្នុងការស្រោចស្រង់។

- **ភាពហិង្សា និងការបង្ហាញនូវភាពលម្អៀង៖** ហិង្សានៅក្នុងសាលារៀនគឺជាមូលហេតុមួយទៀតដែលធ្វើឱ្យសិស្សរៀនយឺត។ កុមារកើតចិត្តស្អប់ចំពោះគ្រូ និងលែងមានចិត្តចង់សិក្សាដោយសារតែការប្រើរំពាត់ ការប្រើពាក្យសម្តីសម្លុតគំរាមគំហែងធ្វើឱ្យកុមារគេងសុបិន្តអាក្រក់ជាញឹកញាប់ ហើយជួនកាលអាចឈានដល់បញ្ហាផ្នែកសតិអារម្មណ៍ បញ្ហាផ្លូវចិត្តដែលជះឥទ្ធិពលដល់លទ្ធភាពនៃការទទួលចំណេះដឹង។ គ្រូខ្លះមានភាពលម្អៀងចំពោះសិស្សដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការសិក្សាដោយសិស្សមានចិត្តស្អប់ទាំងគ្រូទាំងមុខវិជ្ជាសិក្សា ព្រមទាំងមានចិត្តច្រណែនចំពោះសិស្សដទៃ។

## ២.៤ តួនាទី និងភារកិច្ចរបស់នាយកសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូប្រចាំថ្នាក់ក្នុងការជួយសិស្សរៀនយឺត

### ២.៤.១.នាយកសាលា

នាយកសាលាជាប្រតិភូរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលទទួលបន្ទុកអភិបាលសាលារៀនមួយ ជាប្រមុខអង្គភាព ជាតំណាងអំណាចរដ្ឋបាលដែលមានទំនួលខុសត្រូវខ្ពស់ក្នុងការចាត់ចែងការងារដឹកនាំគ្រប់គ្រងគ្រប់សកម្មភាពរបស់សាលារៀន។ នាយកសាលាជាមនុស្សដ៏សំខាន់ម្នាក់ក្នុងការធ្វើឱ្យមានដំណើរការល្អនៅក្នុងសាលារៀនក៏ដូចជាការបង្រៀនរបស់លោកគ្រូ អ្នកគ្រូឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសការចូលរួមក្នុងការជួយសិស្សរៀនយឺតឱ្យទទួលបាននូវប្រសិទ្ធភាពក្នុងការសិក្សារបស់គេ (**ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ,២០១៦**) ។ ដូច្នេះដើម្បីឱ្យកម្រិតនៃការជួយសិស្សរៀនយឺតមានប្រសិទ្ធភាពខ្ពស់នាយកសាលាត្រូវ៖

- ក្តាប់ឱ្យបានច្បាស់អំពីស្ថានភាពសិស្សរៀនយឺតតាមថ្នាក់ដោយឱ្យគ្រូប្រចាំថ្នាក់ស្រង់ស្ថិតិសិស្សខ្សោយរបស់ខ្លួនឱ្យបានមុនដំណាច់ខែនីមួយៗ និងធ្វើតារាងតាមដាន ប្រៀបធៀបលទ្ធផលតាមលំដាប់ខែ។

- ប្រជុំផ្សព្វផ្សាយ និងសិក្សាពីមូលហេតុដែលពាក់ព័ន្ធនឹងអត្រាធ្លាក់មធ្យមភាគប្រចាំខែតាមថ្នាក់ កំណត់វិធានការ និងបែងចែកការទទួលខុសត្រូវដល់អ្នកពាក់ព័ន្ធនានា (គ្រូ-សហគមន៍) ដោយធ្វើផែនការ និងលើកទិសដៅជាមួយនាយករង ប្រធានក្រុមបច្ចេកទេស គ្រូ សហគមន៍ ក្នុងការរំលស់ចំនួនសិស្សធ្លាក់មធ្យមភាគក្នុងមួយខែម្តង។
- ចុះអធិការកិច្ច រៀបចំប្រជុំក្រុមបច្ចេកទេសដោយកំណត់ប្រធានបទ និងខ្លឹមសារច្បាស់លាស់ រៀបចំឱ្យមានថ្នាក់និទស្សន៍ជូនគ្រូបង្រៀន រាយការណ៍អំពីលទ្ធផលដែលទទួលបាន រៀបចំកែលំអរាល់ចំណុចអវិជ្ជមានជូនគ្រូបង្រៀនរួមទាំងអ្នកពាក់ព័ន្ធគ្រប់ភាគី។ (**សេចក្តីណែនាំស្តីពីការជួយសិស្សខ្សោយស្របពេលសិក្សា លេខ ១៧៦៨អយក-សណន, ២០០៥)**

## ២.៤.២. ប្រធានក្រុមបច្ចេកទេស

ក្រុមបច្ចេកទេសគឺជាបណ្តុំគ្រូបង្រៀនតាមកម្រិតថ្នាក់នៅតាមគ្រប់សាលាដើម្បីជួយគ្នាទៅវិញទៅមកពេលសមាជិកក្រុមជួបប្រទះនឹងការលំបាកក្នុងការងារបង្រៀននិងរៀនរបស់កុមារ។ ក្នុងការជួយសិស្សរៀនយឺតប្រធានក្រុមបច្ចេកទេសត្រូវមានភារកិច្ច៖

- ណែនាំផ្សព្វផ្សាយពីកម្មវិធីសិក្សាដើម្បីកំណត់សមត្ថភាពសិស្សតាមកម្រិតថ្នាក់ផ្អែកតាមកម្មវិធីគោលរបស់ក្រសួង និងស្ថានភាពជាក់ស្តែង
- ប្រមូល និងសិក្សាទិន្នន័យព័ត៌មានតាមកម្រិតថ្នាក់ស្តីពីលទ្ធផលសិក្សារបស់សិស្សពិសេសលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា
- ធ្វើផែនការជួយសិស្សរៀនយឺតដោយសហការណ៍ជាមួយនាយក គ្រូ សហគមន៍
- ដឹកនាំប្រជុំក្នុងក្រុមបច្ចេកទេសតាមកម្រិតថ្នាក់ដើម្បីរកដំណោះស្រាយទាក់ទងនឹងការលំបាករបស់សិស្សរៀនយឺត
- ធ្វើថ្នាក់និទស្សន៍តាមកម្រិតថ្នាក់ដើម្បីបង្ហាញបទពិសោធនៃការជួយសិស្សរៀនយឺតក្នុងថ្នាក់
- ជួយរៀបចំ និងផ្តល់យោបល់លើកិច្ចតែងការបង្រៀន និងកសាងសំភារឧទេសសម្រាប់គ្រូប្រើប្រាស់ក្នុងការជួយសិស្សរៀនយឺតតាមថ្នាក់
- ប្រមូលចងក្រងទុកជាបទពិសោធ និងសិក្សាសំណូមពរថ្មីៗរបស់គ្រូបង្រៀនសំរាប់កសាងផែនការប្រជុំបច្ចេកទេស

- បូកសរុបវាយតម្លៃលើការរីកចំរើន និងផលប៉ះពាល់នៃការជួយសិស្សរៀនយឺតស្រប ពេលប្រចាំខែ និងប្រចាំឆ្នាំតាមកម្រិតថ្នាក់ និងរាយការណ៍ជូនគណៈនាយកដើម្បីលើក ទិសដៅថ្មី
- ជួយគ្រូឱ្យចេះវាយតម្លៃខ្លួនឯងលើការរៀននិងបង្រៀន។

**(ឯកសារជួយសិស្សខ្សោយស្របពេលសិក្សា, ២០០៩ )**

## ២.៤.៣. គ្រូប្រចាំថ្នាក់

ថ្នាក់រៀននីមួយៗត្រូវមានគ្រូទទួលបន្ទុកម្នាក់ដែលចាត់តាំងដោយនាយកសាលារៀន។ នៅបឋមសិក្សាគ្រូប្រចាំថ្នាក់នីមួយៗមានភារកិច្ចជាសិក្ខាបនធារីគ្រប់មុខវិជ្ជាផង និងជាគ្រូទទួលបន្ទុកថ្នាក់ផង។ ក្នុងភារកិច្ចជាសិក្ខាបនធារីគាត់គឺជាកម្លាំងអប់រំដ៏ចំបងក្នុងការជួយសិស្សានុសិស្សឱ្យសម្រេចបាននូវលទ្ធផលនៃការសិក្សារបស់ពួកគេប្រកបដោយជោគជ័យ។ ក្នុងការជួយសិស្សរៀនយឺតគ្រូទទួលបន្ទុកថ្នាក់ត្រូវ៖

- ក្តាប់ឱ្យបានច្បាស់ចំនួនសិស្សខ្សោយក្នុងខែនីមួយៗនិងស្ថានភាពគ្រួសាររបស់គេ
- ក្តាប់ឱ្យបានច្បាស់ចំនួនសិស្សខ្សោយលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាទៅតាមសមត្ថភាពនីមួយៗដោយធ្វើជាតារាង សិក្សាលើមូលហេតុដែលនាំឱ្យសិស្សទាំងនោះរៀនខ្សោយ( ឈឺ ឈប់ច្រើន អន់បញ្ញា...)
- រាយការណ៍ជូនប្រធានក្រុមបច្ចេកទេស នាយកសាលា និងមាតាបិតាសិស្សនូវព័ត៌មាននានាដែលទាក់ទងនឹងចំណុចវិជ្ជមាន និងអវិជ្ជមានរបស់សិស្ស កំណត់អំពីវិធីដែលត្រូវជួយទៅតាមប្រភេទនៃការលំបាករបស់សិស្សនីមួយៗឱ្យបានសមស្រប
- ពង្រឹងការងាររដ្ឋបាលថ្នាក់ដោយចុះអវត្តមានឱ្យបានទៀងទាត់ និងធ្វើទំនាក់ទំនងជាមួយមាតាបិតាសិស្សឱ្យបានទាន់ពេលវេលា
- ពង្រឹងការងារបង្រៀន (ធ្វើកិច្ចតែងការបង្រៀន ការប្រើសំណួរ ការចាត់តាំងសកម្មភាព និងការប្រើប្រាស់សម្ភារឧបទេស)
- ពង្រឹងសកម្មភាពរៀន (ធ្វើការងារបុគ្គល ក្រុម ដៃគូក្នុងថ្នាក់ ក្រៅថ្នាក់...) ឱ្យបានគ្រប់ម៉ោងសិក្សា ពង្រឹងការងារទទួលខុសត្រូវរបស់សិស្សក្នុងការជួយសិស្សខ្សោយ (អប់រំតាមផ្ទះ ជួយក្នុងសាលា ក្នុងថ្នាក់នៅពេលសិស្សខ្សោយមានបញ្ហា) ដោយធ្វើការណែនាំឱ្យបានច្បាស់លាស់

➢ បង្កើនភាពយោគយល់និងស្និទ្ធស្នាលជាមួយសិស្សតាមរយៈការសួរនាំ ការផ្ដល់ឱកាសឱ្យចូលរួមធ្វើការងារ ការផ្ដល់យោបល់ និងការលើកទឹកចិត្ត ធ្វើតារាងតាមដានលទ្ធផលនៃការកាត់បន្ថយភាគរយនៃការធ្លាក់មធ្យមភាគប្រចាំខែ

➢ បូកសរុប និងវាយតម្លៃការរីកចម្រើន ផលប៉ះពាល់នៃការជួយសិស្សរៀនយឺតជូនប្រធានក្រុមបច្ចេកទេស និងនាយកសាលា។ (**សេចក្ដីណែនាំស្ដីពីការជួយសិស្សខ្សោយស្របពេលសិក្សា លេខ ១៧៦៨អយក-សណន, ២០០៥**)

## ២.៥.ការជួយកូនរៀនយឺតពីសំណាក់ឪពុកម្ដាយ រឺអាណាព្យាបាល

ការចូលរួមយ៉ាងយកចិត្តទុកដាក់ពីឪពុកម្ដាយ ឬអាណាព្យាបាលក្នុងការជួយកូនៗរបស់ខ្លួនដែលរៀនយឺតគឺជាសញ្ញាណដ៏សំខាន់បំផុតដែលអាចកំណត់បាននូវភាពជោគជ័យនៃលទ្ធផលសិក្សារបស់កូនពួកគាត់។ កុមារដែលមិនទទួលបាននូវការគាំទ្រ និងការស្វែងយល់ឱ្យបានទូលំទូលាយទៅលើការសិក្សារបស់គេពីសំណាក់ឪពុកម្ដាយនឹងអាចឈានទៅរកភាពបរាជ័យក្នុងការសិក្សាយ៉ាងធ្ងន់ធ្ងរដែលឈានដល់ការជះឥទ្ធិពលមិនល្អដល់អនាគតរបស់ពួកគេទៀតផង។ Michelle Crossley, (2015) បានបរិយាយពីមធ្យោបាយដែលឪពុកម្ដាយគួរធ្វើដើម្បីជួយកូនៗរបស់ពួកគេដែលរៀនយឺតនៅផ្ទះ។ ចំណុចដែលសំខាន់ក្នុងការជួយកូនៗរបស់ខ្លួនដែលរៀនយឺតនោះគឺត្រូវទទួលយកនូវភាពខ្វះខាតរបស់គេហើយពួកគេក៏មិនត្រូវការការអប់រំពិសេសនោះដែរ ប៉ុន្តែវាទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសជាមួយនឹងភាពអំណត់ ការលើកទឹកចិត្ត និងភាពជឿជាក់ទៅលើពួកគេ។

- **ផ្ដល់តម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង៖** វាជារឿងសាមញ្ញទៅហើយដែលសិស្សរៀនយឺតមិនមានលទ្ធភាពក្នុងការកំណត់គោលដៅសិក្សាច្បាស់លាស់ដោយសារតែពុំមានបំរុងប្រយ័ត្នខ្ពស់ៗក្នុងនាមជាឪពុកម្ដាយ ឬអាណាព្យាបាលវាជារឿងចាំបាច់បំផុតក្នុងការមិនបង្ខំកូនរបស់ខ្លួនដាច់ខាតត្រូវតែជំនះឱ្យបាននូវបញ្ហាប្រឈមនឹងលទ្ធភាពរបស់គេ។ ការសរសើរចំពោះសមិទ្ធផលជោគជ័យតិចតួចដែលពួកគេសម្រេចបាន បានកសាងទំនុកចិត្ត និងបង្ហាញពីការធ្វើឱ្យប្រសើរឡើងជានិរន្តន៍នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវភាពជោគជ័យរបស់ពួកគេ។
- **ពន្យាការកំហិតពេលវេលា៖** ការវិនិច្ឆ័យទៅលើលទ្ធភាពរបស់កូន និងការជួយពួកគេឱ្យបំពេញកិច្ចការសាលាជាមួយនឹងការពន្យាពេលវេលាកំណត់បានធ្វើឱ្យពួកគេមានអារម្មណ៍រីករាយ ប៉ុន្តែក៏មិនត្រូវអនុញ្ញាតឱ្យពួកគេមិនប្រើនូវសក្ដានុពលរបស់ខ្លួនដែរ។

- **ដឹងពីចំណាប់អារម្មណ៍របស់កូន៖** កុមារដែលរៀនយឺតងាយនឹងបែកបំរុងប្រយ័ត្ន។ ការកំណត់បាននូវសកម្មភាពដែលកូនចូលចិត្ត និងលើកទឹកចិត្តពួកគេឱ្យចូលរួមនឹងសកម្មភាពទាំងនោះនៅផ្ទះអាចធ្វើឱ្យប្រសើរឡើងនូវឥរិយាបថរបស់ពួកគេ។
- **រៀបចំតារាងពេលវេលា និងជួយបង្រៀនបន្ថែម៖** ការបង្កើតតារាងដែលកំណត់នូវពេលវេលាសម្រាប់សកម្មភាពប្រចាំថ្ងៃ និងការជួយបង្រៀនបន្ថែមជាស្មារតីទទួលខុសត្រូវ និងជំរុញទឹកចិត្តពួកគេឱ្យបំពេញកិច្ចការសាលាដែលគ្រូដាក់ឱ្យព្រមទាំងបានជួយគេនូវអ្វីដែលមិនទាន់ច្បាស់ពីសាលា។

ជារួមមកដោយសារតែរយៈពេលនៃការផ្ចង់ស្មារតីរបស់សិស្សរៀនយឺតមានរយៈពេលខ្លី ដូច្នេះការឱ្យពួកគេធ្វើការក្នុងថេរវេលាខ្លីតែច្រើនដង ទទួលបានលទ្ធផលប្រសើរជាងឱ្យពួកគេធ្វើការតែម្តងក្នុងរយៈពេលវែង។ ទំនួលខុសត្រូវដ៏សំខាន់មួយរបស់ឪពុកម្តាយ ឬអាណាព្យាបាលគឺត្រូវទំនាក់ទំនងនឹងគ្រូប្រចាំថ្នាក់ដើម្បីស្វែងយល់ថាតើមានកន្លែងណាផ្សេងទៀតដែលកូនរបស់ខ្លួនទាមទារជំនួយ។

## ២.៦. សកម្មភាពជួយសិស្សរៀនយឺតស្របពេលលើមុខវិជ្ជាភាសាខ្មែរ

### ក. សមត្ថភាពនិយាយ

**បញ្ហា៖** សិស្សមិនទាន់ចេះសន្ទនាតាមស្ថានភាពជាក់ស្តែង និងខ្លឹមសារសន្ទនាគំរូមិនស្របនឹងស្ថានភាពជាក់ស្តែង។

**ដំណោះស្រាយ៖** ក្នុងករណីនេះគ្រូត្រូវឱ្យសសិស្សខ្សោយអនុវត្តន៍ការសន្ទនាគំរូឱ្យបានញឹកញាប់និងគ្រប់ៗគ្នា គ្រូឱ្យសិស្សឆ្លើយសំនួរយល់ដឹងពីសេចក្តីរបស់អត្ថបទក្រោយការអាន សំយោគនិងកែសម្រួលនូវរាល់សកម្មភាពខុសឆ្គងព្រមទាំងផ្តល់ឱកាសឱ្យសិស្សខ្សោយជ្រើសរើសដៃគូសន្ទនា ឱ្យសិស្សសាកល្បងសន្ទនាតាមស្ថានភាពជាក់ស្តែងដោយខ្លួនឯងតាមខ្លឹមសារគំរូខ្លីៗនិងលើកសរសើរក្រោយការសន្ទនាចប់។ គ្រូត្រូវស្វែងយល់ឡើងវិញពីវិធីបង្រៀនក្នុងសៀវភៅគ្រូ សៀវភៅសិស្ស ឯកសារពាក់ព័ន្ធ និងឯកសារបំប៉នប្រធានក្រុមបច្ចេកទេសដើម្បីធ្វើកិច្ចតែងការបង្រៀនឱ្យបានល់អិតសមស្របតាមតម្រូវការសិស្សរៀនយឺត។ គ្រូត្រូវមានទស្សនៈទូលាយក្នុងការសម្របសម្រួលខ្លឹមសារក្នុងសៀវភៅសិស្សទៅតាមស្ថានភាព ជីវភាពក្នុងសហគមន៍ ។ ការបង្កើតខ្លឹមសារថ្មីត្រូវធ្វើសកម្មភាពយឺតៗតាមដែលសិស្សរៀនយឺតទទួលបានដោយផ្តល់ឱកាសឱ្យពួកគេសន្ទនា ឬឆ្លើយនឹងសំណួរដោយប្រើភាសាផ្ទាល់ខ្លួនពួកគេឱ្យបានច្រើនព្រមទាំងទុកពេលឱ្យពួកគេបាននឹកឃើញសំនួនពាក្យពេចន៍ និងសេចក្តីដែលត្រូវ

និយាយឆ្លើយឆ្លងជាមួយដៃគូរបស់ខ្លួនដោយមិនត្រូវទាមទារនូវភាពសុក្រឹតពេកទេក្នុងការប្រើប្រាស់ភាសាដើម្បីកុំឱ្យសិស្សបាត់ភាពក្លាហាន។

## ខ. សមត្ថភាពស្តាប់

**បញ្ហា៖** ការញែកសូរពុំបានច្បាស់លាស់

**ដំណោះស្រាយ៖**

- ទំលាប់សិស្សឱ្យស្តាប់តាមសូរសំលេងព្យញ្ជនៈ និងស្រៈឱ្យបានច្បាស់លាស់តាមគំរូដោយគ្រូហៅឈ្មោះវត្ថុផ្សេងៗដែលចាប់ផ្តើមដោយសូរដូចគ្នាហើយឱ្យសិស្សប្រាប់ឈ្មោះផ្សេងៗដែលចាប់ផ្តើមដោយសូរដដែល។
- គ្រូត្រូវអានសូរស្រៈ សូរព្យញ្ជនៈឱ្យបានច្បាស់ៗជាគំរូដល់សិស្សក្នុងញែកសូរពាក្យនិងសូរព្យាង្គ និងទំលាប់សិស្សឱ្យមើលមាត់គ្រូពេលគ្រូបន្លឺជាគំរូ។ សិស្សត្រូវប្រើអក្សរចល័តដើម្បីឱ្យការញែកសូរបានច្បាស់លាស់ និងដើម្បីឱ្យពួកគេយល់ពីទំនាក់ទំនងរវាងសំនេរនិងសូរ។

**បញ្ហា៖** សិស្សមិនយល់ខ្លឹមសាររឿងនិទាន (កណាព្យ អត្ថបទអធិប្បាយមួយចំនួន)

**ដំណោះស្រាយ៖**

- គ្រូត្រូវពន្យល់ពាក្យពិបាក ប្រើបរិបទ លើកឧទាហរណ៍ បំផុសសំណួរ ប្រើសំភារៈដើម្បីឱ្យសិស្សឆាប់យល់ន័យ។ ជាមួយគ្នានេះដែរគ្រូត្រូវចាំរឿងឱ្យបានច្បាស់មុនពេលមកនិទានឱ្យសិស្សស្តាប់។
- ឱ្យសិស្សប្រាប់ចំណងជើងរឿងភ្លាមៗក្រោយពីគ្រូប្រាប់ និងប៉ាន់ស្មានខ្លឹមសារ រួចគ្រូកត់ត្រាចំលើយប៉ាន់ស្មាននៅលើក្តារខៀន
- និទានមួយផ្នែកម្តងៗដើម្បីឱ្យសិស្សមានពេលគិត ចងចាំសេចក្តីលំអិត ព្រឹត្តិការណ៍នៃរឿង។ គ្រូត្រូវឱ្យសិស្សសាកល្បងនិទានឡើងវិញមួយផ្នែកម្តងៗដោយប្រើសំណួរបំផុសដើម្បីកុំឱ្យពួកគេភ្លេចសេចក្តីលំអិតនៃរឿងព្រមទាំងជួយសម្របសម្រួលសំយោគបន្ថែមដើម្បីឱ្យសិស្សរៀនយឺតចាប់ខ្លឹមសារបាន។
- ឱ្យសិស្សផ្ទៀងផ្ទាត់ចំលើយប៉ាន់ស្មានទៅនឹងចំលើយដែលប្រាប់ខ្លឹមសារពិត

**បញ្ហា៖** សិស្សឆ្លើយសំនួរមិនបានក្បោះក្បាយ

**ដំណោះស្រាយ៖**

- គ្រូប្រើសំណួរខ្លីៗមានន័យច្បាស់លាស់ដោយនិយាយមួយៗយឺតៗនិងឱ្យសិស្សនិយាយឡើងវិញនូវខ្លឹមសារសំនួរដែលគ្រូបានសួរដើម្បីស្ទាបស្ទង់ការយល់ដឹង និងការចងចាំរបស់សិស្ស។
- ផ្តល់ឱកាសឱ្យសិស្សបានបកស្រាយនូវគំនិតរបស់ខ្លួនទាក់ទងទៅនឹងចម្លើយ ឬការរកឃើញរបស់គេដោយមិនត្រូវទាមទារយកតែចម្លើយតាមសៀវភៅ ឬតាមគំនិតរបស់គ្រូទាំងស្រុង ឬតាមចម្លើយល្អដូចសិស្សពូកែនោះទេ។

## គ. សមត្ថភាពអាន

**បញ្ហា៖** សិស្សអានតាមសូរព្យញ្ជនៈ ស្រៈ និងពាក្យមិនបានត្រឹមត្រូវ

**ដំណោះស្រាយ៖** ឱ្យសិស្សអានពាក្យតាមភាសាសរសេរដដែលៗរហូតបានត្រឹមត្រូវច្បាស់លាស់។ ចំពោះពាក្យពិបាករាល់ពេលដែលហាត់អានត្រូវឱ្យសិស្សមើលមាត់គ្រូនិងព្យាយាមកែលំអនូវរាល់អំណានខុសរបស់សិស្ស។

**បញ្ហា៖** សិស្សច្រលំតួអក្សរ

**ដំណោះស្រាយ៖** ហ្វឹកហាត់អានតួអក្សរដោយចំណាំព្យញ្ជនៈដែលងាយច្រលំគ្នា និងទីតាំងស្រៈនៅក្នុងពាក្យ ព្រមទាំងឱ្យសិស្សហ្វឹកហាត់អានពាក្យចំណាំតួអក្សរដែលគ្មានសូរ ឧទាហរណ៍៖ ការ រៀបការ សភាពការណ៍ ភូមិ ហេតុ .....។

**បញ្ហា៖** សិស្សមិនចេះធ្វើអក្ខរវិញ្ញាស

**ដំណោះស្រាយ៖** ឱ្យសិស្សធ្វើអក្ខរវិញ្ញាសឱ្យបានញឹកញាប់ ពន្យល់ន័យឱ្យបានគ្រប់ៗគ្នាព្រមទាំងឱ្យសិស្សសរសេរលើក្តារឆ្នួននៅពេលបង្រៀនវាក្យស័ព្ទដើម្បីពង្រឹងពុទ្ធិផ្នែកអក្ខរាវិរុទ្ធ។

**បញ្ហា៖** សិស្សមិនចេះរកគំនិតសំខាន់បង្កប់របស់កថាខណ្ឌ

**ដំណោះស្រាយ៖**

- គ្រូរំលឹកពីអ្វីដែលហៅថាគំនិតសំខាន់របស់កថាខណ្ឌ (បញ្ញត្តិ ឬនិយមន័យ) ដោយលើកឧទាហរណ៍បញ្ជាក់ដើម្បីឱ្យសិស្សបកស្រាយតាមគំនិតដែលពួកគេយល់។
- គ្រូឱ្យសិស្សអានល្បះម្តងមួយៗក្នុងកថាខណ្ឌដោយបំផុសសំណួរឱ្យសិស្សប្រាប់ពីគំនិតសំខាន់ៗរបស់ល្បះ។
- ឱ្យសិស្សអានប្រធានលំហាត់សំនេរកថាខណ្ឌនិងប្រាប់ពីសំណុចសំខាន់ៗរបស់ប្រធាននោះដោយសិស្សពូកែនិងគ្រូជួយបំពេញបន្ថែម។

- សិស្សពិភាក្សាដើម្បីកំណត់អំពីគំនិតសំខាន់បង្កប់រូចរាយការណ៍ បន្ទាប់មកគ្រូសំយោគគំនិតដែលទាក់ទងនឹងប្រធានរួមដែលមិនបង្ហាញតាមល្បះណាមួយក្នុងកថាខណ្ឌបែបនេះគេហៅថាគំនិតបង្កប់។
- ឱ្យសិស្សខ្សោយនិយាយក្រោយការអានដើម្បីបង្ហាញគំនិតសំខាន់បង្កប់របស់អត្ថបទដោយមានជំនួយពីសិស្សដទៃទៀតដែលនៅក្នុងក្រុម និងគ្រូបង្រៀន។ គ្រូផ្តល់លំហាត់ដែលមានលំនាំដូចគ្នាឱ្យបានច្រើនដោយចាត់តាំងការពិភាក្សា និងធ្វើរបាយការណ៍។

## ឃ. សមត្ថភាពសរសេរ

**បញ្ហា៖** សិស្សសរសេរតួព្យញ្ជនៈ ស្រៈខុសពីការណែនាំតាមសៀវភៅសិស្ស

**ដំណោះស្រាយ៖**

- គ្រូឱ្យសិស្សសង្កេតដើម្បីស្គាល់តួ រាងអក្សរដែលទាក់ទងទៅនឹងសូរ ឬភាពខុសគ្នាពីអក្សរមួយទៅអក្សរមួយ ឧទាហរណ៍៖ ក ត គ ភ យ឴ យ ឈ បម.......
- ឱ្យសិស្សសរសេរតាមការណែនាំរបស់គ្រូយឺតៗច្បាស់លាស់តាមលំដាប់ចលនា និងទិសសំណេរ ដោយឱ្យសិស្សហ្វឹកហាត់ចលនាដៃ និងម្រាមដៃក្នុងការសរសេរតួព្យញ្ជនៈ ស្រៈឱ្យបានច្រើនដង។
- ផ្តល់ឱកាសឱ្យសិស្សសួរ និងដោះស្រាយនូវរាល់សំណួមពររបស់សិស្សភ្លាមៗព្រមទាំងពិនិត្យ និងកែលំអកំហុសសិស្សក្នុងពេលសរសេរ។

**បញ្ហា៖** សិស្សរើសពាក្យមកបំពេញល្បះពុំបានត្រឹមត្រូវតាមន័យរបស់វា

**ដំណោះស្រាយ៖** ឱ្យសិស្សគិតឡើងវិញដោយវិភាគមុននឹងសំរេចយកពាក្យណាមួយមកបំពេញក្នុងល្បះនិងផ្តល់ឱកាសឱ្យសិស្សខ្សោយសហការជាមួយសិស្សពូកែ

**បញ្ហា៖** សិស្សរសេរកថាខណ្ឌចេញពីអត្ថបទពាក្យកាព្យមកជាពាក្យរាយមិនបានត្រឹមត្រូវ (មិនយល់ពីបញ្ញត្តិ)

**ដំណោះស្រាយ៖**

- គ្រូត្រូវលើកយកអត្ថបទពាក្យកាព្យដែលជាគំរូឱ្យសិស្សអានឡើងវិញ ព្រមទាំងបំផុសសំនួររកសេចក្តីលំអិតតាមលំដាប់លំដោយ
- ឱ្យសិស្សខ្សោយនិយាយពីសេចក្តីលំអិតរបស់អត្ថបទពាក្យកាព្យឡើងវិញតាមលំដាប់លំដោយ ដោយគ្រូមិនត្រូវទាមទារភាពសុក្រឹតពេកទេក្នុងការប្រើប្រាស់ភាសាផ្ទាល់ខ្លួនរបស់កុមារ
- សិស្សសរសេរតាមគំនិតដែលបានឆ្លើយជាអត្ថបទពាក្យរាយជាមួយដៃគូ

- គ្រូវាយតម្លៃនិងសរសើរលើកទឹកចិត្ត។ **(ឯកសារជួយសិស្សខ្សោយស្របពេលសិក្សាឆ្នាំ ២០០៨)**

## ២.៧. សកម្មភាពជួយសិស្សរៀនយឺតស្របពេលលើមុខវិជ្ជាគណិតវិទ្យា

**បញ្ហា៖** សិស្សភ្លេចខ្លឹមសារមេរៀនគណិតវិទ្យាមិនបាន (ថ្នាក់ទី១ ទី២)

**ដំណោះស្រាយ៖**

- គ្រូត្រូវនិទានរឿងខ្លីៗដែលនិយាយពីចំនួន និងបង្ហាញសកម្មភាពខ្លះៗដែលទាក់ទងទៅនឹងការរាប់បញ្ចូល ឬការដកចំនួនដោយឱ្យសិស្សខ្សោយផ្គូរផ្គងចំនួន វត្ថុ និងលេខ
- ឱ្យសិស្សរៀនយឺតធ្វើសកម្មភាពដដែលៗនេះឡើងវិញ

**បញ្ហា៖** សិស្សមិនយល់ មិនចេះរៀបលំដាប់ចំនួន

**ដំណោះស្រាយ៖** ឱ្យសិស្សហ្វឹកហ្វាត់សរសេរលំដាប់ចំនួន (បុគ្គល ដៃគូ) ពីធំទៅតូច ពីតូចទៅធំ និងបញ្ជាក់ប្រាប់ពីរបៀបកំណត់ចំនួននេះដោយប្រើសំភារៈនិងល្បែងសិក្សា។

**បញ្ហា៖** ការកំណត់ខ្ទង់ និងតម្លៃខ្ទង់ សិស្សមិនចាំខ្ទង់ មិនស្គាល់តម្លៃរបស់ខ្ទង់ និងមិនចេះធ្វើប្រមាណវិធីលើចំនួន

**ដំណោះស្រាយ៖**

- មុននឹងឈានដល់ការធ្វើប្រមាណវិធីត្រូវឱ្យសិស្សហ្វឹកហ្វាត់កំណត់តម្លៃខ្ទង់

  ឧទាហរណ៍៖ ៤៦៨

  ៨ រាយ ព្រោះ៨នៅក្នុងខ្ទង់រាយ មានតម្លៃ ៨

  ៦ ដប់ ព្រោះ៦ នៅក្នុងខ្ទង់ដប់ មានតម្លា ៦០

  ៤ រយ ព្រោះ៤ នៅក្នុងខ្ទង់រយ មានតម្លៃ៤០០

  សរសេរជាទំរង់ពង្រាយ៖ ៤៦៨ = ៤០០+៦០+៨
- ផ្តល់ឧទាហរណ៍ប្រហាក់ប្រហែល និងឱ្យសិស្សកំណត់តម្លៃឱ្យបានច្រើនដង
- ពេលសិស្សយល់តម្លៃខ្ទង់ ចេះប្រាប់តម្លៃលេខតាមខ្ទង់ និងចេះសរសេរចំនួនតាមទំរង់ពង្រាយបានត្រឹមត្រូវហើយ គ្រូអាចឈានទៅឱ្យសិស្សហ្វឹកហ្វាត់ធ្វើប្រមាណវិធីតាមទំរង់ពង្រាយបាន។

**បញ្ហា៖** សិស្សមិនចេះបំបែកឯកតារង្វាស់រង្វាល់

**ដំណោះស្រាយ៖**

- គ្រូរំលឹកពីបញ្ញត្តិ និងពាក្យគន្លឹះរង្វាស់រង្វាល់: ម៉ែត ម៉ែតការេ លីត ......។

- គ្រូយកបន្ទាត់ ឬម៉ែតមកចង្អុលបង្ហាញ និងហ្វឹកហ្វាត់សិស្សឱ្យស្គាល់ច្បាស់ពីខ្នាតរង្វាស់ម៉ែត និងណែនាំឱ្យសិស្សចេះគូសតារាងរង្វាស់ម៉ែត ម៉ែតការេ លីត ។ល។
- ដឹកនាំសិស្សបំពេញលេខក្នុងតារាងតាមលំដាប់ និងការបំពេញចំនួនសូន្យទៅតាមឯកតានៅក្នុងខ្ទង់ដែលគ្មានសូន្យ។

**បញ្ហា៖** សិស្សមិនស្គាល់សញ្ញា ឬគំនូសផ្សេងៗនៅលើរូបធរណីមាត្រ

**ដំណោះស្រាយ៖**

- គ្រូឱ្យសិស្សសាក់ល្បងរក និងកំណត់សញ្ញាផ្សេងៗនៅលើរូបធរណីមាត្រ និងឱ្យសិស្សសាកល្បងគូសសញ្ញា និងប្រាប់ពីអត្ថន័យនៃសញ្ញានោះឡើងវិញ។
  ឧទាហរណ៍៖ ជ្រុងពីរដែលមានគំនូសកាត់ដូចគ្នាជាជ្រុងប៉ុនគ្នា

**បញ្ហា៖** សិស្សមិនចេះធ្វើចំណោទ

**ដំណោះស្រាយ៖**

- ទំលាប់សិស្សឱ្យចេះនិយាយសង្ខេបពីខ្លឹមសារចំណោទដោយភាសាផ្ទាល់របស់គេ
- ណែនាំសិស្សឱ្យចេះប្រមូលព័ត៌មាន ឬបម្រាប់ដែលសំខាន់ និងស្វែងយល់ពីសំណួរតាមដំណាក់នៃជំហានរបស់ចំណោទ និងសំណួរចុងក្រោយ
- គ្រូដឹកនាំធ្វើលំហាត់អនុវត្តឱ្យបានញឹកញាប់ដើម្បីឱ្យគេចេះតែងសំនួរ ចេះរៀបឃ្លាឆ្លើយនឹងសំនួរ ចេះរកអំណះអំណាន
- គ្រូត្រូវរៀបចំប្រធានបទចំណោទដែលសមស្របតាមជីវភាពរស់នៅប្រចាំថ្ងៃ តាមតំបន់ និងតាមសហាគមន៍ដែលគេរស់នៅ
- ទម្លាប់ធ្វើលំហាត់អនុវត្ត រឺចំណោទដែលពាក់ព័ន្ធទៅនឹងប្រមាណវិធីទាំងអស់ដែលបានរៀនរួច។

## ៤.៧. វិធីសាស្ត្រជួយសិស្សរៀនយឺតក្នុងពេលកំពុងបង្រៀន

Emily Listmann, (2019) បានបង្ហាញនូវចំណុចមួយចំនួនដែលជាវិធីសាស្ត្រក្នុងការជួយសិស្សរៀនយឺតក្នុងពេលកំពុងបង្រៀន មានដូចជា៖

1. ថាឡើងវិញនូវចំណុចមេរៀនដែលកំពុងបង្រៀនឱ្យបានលើសពីមួយដង ព្រោះដើម្បីយល់នូវចំណុចណាមួយនៃមេរៀនសិស្សរៀនយឺតត្រូវការឮព័ត៌មានឱ្យបានច្រើនដងជាងសិស្សដទៃទៀត។ ព្យាយាមសួរសំនួរ និងបន្ទរឡើងវិញនូវចំលើយរបស់សិស្ស។

2. ប្រើសំភារៈរូបីៈ ការប្រើប្រាស់សម្ភារៈរូបីក្នុងសកម្មភាពបង្រៀន និងរៀនរបស់គ្រូមានអត្ថប្រយោជន៍យ៉ាងខ្លាំងដើម្បីឱ្យកុមារងាយយល់ ងាយចាប់បាននូវខ្លឹមសារមេរៀនព្រោះពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលយកនូវបញ្ញត្តិអរូបីឡើយ ជាពិសេសគឺកុមាររៀនយឺត។
3. ណែនាំសិស្សនូវចំណុចសំខាន់នៃមេរៀន និងតេស្តៈ មុនពេលចាប់ផ្ដើមមេរៀនគ្រូត្រូវបំព្រួញចំនុចសំខាន់ និងផ្ដល់មគ្គុទេសសិក្សាចំពោះការធ្វើតេស្តដើម្បីឱ្យសិស្សទាំងអស់ដឹងនូវអ្វីដែលត្រូវផ្ដោតអារម្មណ៍ទៅលើ ពិសេសគឺសិស្សរៀនយឺត។
4. ប្រើឧទាហរណ៍ក្នុងជីវភាពជាក់ស្ដែងប្រចាំថ្ងៃពេលបង្រៀនគណិតវិទ្យាៈ គ្រូត្រូវបង្ហាញនូវបញ្ញត្តិគណិតវិទ្យាថ្មីដោយប្រើប្រាស់ស្ថានភាពជីវភាពជាក់ស្ដែងរបស់សិស្ស។
5. រៀបចំសកម្មភាពសិស្សបង្រៀនសិស្ស (សិស្សខ្លាំងជួយសិស្សខ្សោយ)ៈ វាមិនត្រឹមតែជួយសម្រាលបន្ទុករបស់គ្រូក្នុងការជួយសិស្សរៀនយឺតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតភាពស្និទ្ធស្នាលរវាងសិស្សនិងសិស្សទៀតផង។
6. ផ្ដល់កិច្ចការដែលអាចពង្រឹងសមត្ថភាពរបស់គេៈ សិស្សរៀនយឺតមិនគួរត្រូវបានដាក់កិច្ចការដូចសិស្សរៀនពូកែនោះទេ គួរដាក់កិច្ចការណាដែលពួកគេអាចធ្វើបាន និងបន្ថែមកិច្ចដែលលើសសមត្ថភាពរបស់គេបន្តិចត្រឹមមួយ ឬពីរសំណួរជាកិច្ចការដែលគេអាចឱ្យមិត្តភក្តិរបស់គេជាសិស្សមធ្យម ឬពូកែអាចជួយបានដើម្បីជួយពង្រឹងសមត្ថភាពរបស់គេសន្សឹមៗ។
7. សរសើរនូវអ្វីដែលគេធ្វើបានៈ ការលើកទឹកចិត្ត និងការសរសើរជាកាតាលីករមួយជួយជំរុញពួកគេឱ្យមានកម្លាំងចិត្តកាន់តែខ្លាំងក្នុងការចូលរួមសកម្មភាពសិក្សាធ្វើឱ្យពួកគេមានទំនុកចិត្ត និងភាពជឿជាក់លើខ្លួនឯង។ គ្រូត្រូវធ្វើការផ្ដល់ព័ត៌មានត្រឡប់បែបវិជ្ជមាននៅក្នុងគ្រប់ករណីទាំងអស់ ព្រោះថាការស្ដីបន្ទោស និងការរិះគន់បែបអវិជ្ជមាននឹងធ្វើឱ្យគេលែងមានចិត្តចង់ធ្វើនូវអ្វីដែលពួកគេត្រូវធ្វើ។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការជ្រើសរើសសំណាក

ភាគសំណាកសម្រាប់ធ្វើការស្រាវជ្រាវនេះរួមមាន៖

- ថ្នាក់សាលារៀន៖ គណៈនាយកសាលា ០៨នាក់ និងគ្រូបង្រៀនថ្នាក់ទី ១ដល់ទី៦ ចំនួន ៥១នាក់ក្នុងនោះស្រី២២នាក់ស្មើនឹង៤៣.១៤%
- សហគមន៍៖ តំណាងមាតាបិតាសិស្សរៀនយឺត ៣២នាក់ដែលក្នុងនោះមានម្ដាយ២២នាក់ ឪពុក៦នាក់ យាយតា៤នាក់ និងពូមីង២នាក់។

## ៣. ២. ឧបករណ៍ស្រាវជ្រាវ

ដើម្បីសម្រេចតាមគោលបំណង និងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានលើកឡើងពីខាងដើម កម្រងសំណួរចំនួនបីត្រូវបានរៀបចំឡើងតាមបែបបរិមាណវិស័យសម្រាប់នាយកសាលា គ្រូប្រចាំថ្នាក់ និងអាណាព្យាបាលសិស្សរៀនយឺតដោយប្រើប្រាស់សំណួរជាលក្ខណៈទម្រង់បិទ ដាក់លាក់ តាមលំដាប់លំដោយ និងមានសំណួរបន្ថែមជាលក្ខណៈទម្រង់បើកសម្រាប់គណៈនាយកសាលា និងគ្រូប្រចាំថ្នាក់ដើម្បីបង្ហាញពីកិច្ចគាំទ្រ វិធីសាស្ត្រក្នុងការជួយសិស្សរៀនយឺត និងបញ្ហាប្រឈមនានាដែលរារាំងដល់ការជួយពួកគេ។ កម្រងសំណួរត្រូវបានរៀបចំឡើងដោយផ្អែកលើឯកសារជួយសិស្សខ្សោយស្របពេលសិក្សារបស់នាយកដ្ឋានបឋមសិក្សាឆ្នាំ២០០៤ និងឯកសារផ្សេងៗទៀតដែលពាក់នឹងការជួយសិស្សរៀនយឺត។

### ៣.២.១. កម្រងសំនួរសម្រាប់គណៈនាយកសាលា

កម្រងសំនួរនេះចែកចេញជាបួនផ្នែក៖

ក. ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន មាន២សំនួរដោយក្នុងនោះព័ត៌មានដែលត្រូវផ្ដល់មានភេទ និងកម្រិតសិក្សា។

ខ. ផ្នែកទី២៖ អំពីការងារគ្រប់គ្រង មាន៤សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ដឹងអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់នាយកសាលាពាក់ព័ន្ធនឹងសិស្សរៀនយឺតដូចជា ទិន្នន័យសិស្សរៀនយឺត ការស្រង់ស្ថិតិសិស្សរៀនយឺតជាប្រចាំ ការប្រជុំស្វែងរកដំណោះស្រាយជាមួយអ្នកពាក់ព័ន្ធក្នុងការជួយសិស្សរៀនយឺត។

គ. ផ្នែកទី៣៖ ការទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស មាន២សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីទំនាក់ទំនងរវាងនាយកសាលា និងអាណាព្យាបាល

សិស្សរៀនយឺតដូចជាការជួបប្រជុំពិភាក្សាគ្នាអំពីលទ្ធផលសិក្សារបស់សិស្សរៀនយឺត ការផ្ដល់សៀវភៅតាមដានការសិក្សាទៅអាណាព្យាបាលសិស្ស។

ឃ. ផ្នែកទី៤៖ បញ្ហាប្រឈម និងសំណូមពរ មានពីរសំនួរដោយអ្នកស្រាវជ្រាវចង់សិក្សាស្វែងយល់ពីបញ្ហានានាដែលបង្កការរាំងស្ទះដល់ការជួយសិស្សរៀនយឺត។

### ៣.២.២. កម្រងសំនួរសម្រាប់គ្រូប្រចាំថ្នាក់

កម្រងសំនួរនេះចែកចេញជា៤ផ្នែក

ក. ផ្នែកទី១៖ អំពីព័ត៌មានផ្ទាល់ខ្លួន មាន៣សំនួរដោយក្នុងនោះព័ត៌មានដែលត្រូវផ្ដល់មាន ភេទ កម្រិតថ្នាក់ដែលកំពុងបង្រៀន និងកម្រិតសិក្សា។

ខ. ផ្នែកទី២៖ អំពីកិច្ចការរដ្ឋបាលថ្នាក់រៀនមាន៨សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ដឹងអំពីស្ថិតិសិស្សតាមថ្នាក់ ស្ថិតិសិស្សរៀនយឺត អថេរភាពនៃចំនួនសិស្សដើមឆ្នាំ និងបច្ចុប្បន្ន ការតាមដានស្ថានភាពគ្រួសារសិស្សរៀនយឺត មុខវិជ្ជាដែលពួកគេរៀនយឺត របាយការណ៍ស្ដីពីលទ្ធផលសិក្សារបស់សិស្សរៀនយឺតទៅនាយកសាលា ការផ្ដល់ព័ត៌មានទៅឪពុកម្ដាយ ឬអាណាព្យាបាលសិស្ស មធ្យោបាយនៃការធ្វើទំនាក់ទំនងរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាលសិស្សរៀនយឺត ការធ្វើសៀវភៅតាមដានការសិក្សារបស់សិស្ស និងការចុះអវត្តមានសិស្សប្រចាំថ្ងៃ។

គ. ផ្នែកទី៣៖ អំពីសកម្មភាពបង្រៀន និងរៀន មាន៦សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញនូវការយកចិត្តទុកដាក់របស់គ្រូទៅលើការបង្រៀនដូចជា ការធ្វើកិច្ចតែងការជាប្រចាំ សកម្មភាពនៃការពិភាក្សាក្រុម ការចាត់តាំងសកម្មភាពសិស្សខ្លាំងជួយសិស្សខ្សោយ ការប្រើប្រាស់សម្ភារឧបទេសក្នុងម៉ោងបង្រៀន ការយកចិត្តទុកដាក់ទៅលើសិស្សរៀនយឺត ការដាក់កិច្ចការផ្ទះ ការត្រួតពិនត្យកិច្ចការផ្ទះឡើងវិញ និងតេស្តប្រចាំខែ។

ឃ. ផ្នែកទី៤៖ បញ្ហាប្រឈមមាន១សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ដឹងអំពីបញ្ហាប្រឈមនានាដែលរារាំងដល់ការជួយសិស្សរៀនយឺត។

### ៣.២.៣. កម្រងសំនួរសម្រាប់ឪពុកម្ដាយ ឬអាណាព្យាបាលសិស្សរៀនយឺត

កម្រងសំនួរនេះមាន៣ផ្នែក

ក. ផ្នែកទី១៖ អំពីព័ត៌មានផ្ទាល់ខ្លួន មាន២សំនួរដោយក្នុងនោះព័ត៌មានដែលត្រូវផ្ដល់មានស្ថានភាពរបស់អ្នកបំពេញកម្រងសំនួរ (អ្នកបំពេញកម្រងសំនួរត្រូវជាអ្វីនឹងសិស្សរៀនយឺត) និងមុខរបរ ។

ខ. ផ្នែកទី២៖ អំពីការជួយកូននៅផ្ទះ មាន៣សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ដឹងអំពីការយកចិត្តទុកដាក់របស់ឪពុកម្តាយទៅលើការសិក្សារបស់កូននៅផ្ទះ ដូចជាការពិនិត្យទៅលើសៀវភៅសិក្សារបស់កូន ការជួយបង្រៀនកូនបន្ថែមនៅផ្ទះ ការជួយកិច្ចផ្ទះរបស់កូន។

គ. ផ្នែកទី៣៖ ការទំនាក់ទំនងជាមួយសាលារៀន និងសំណូមពរ មាន៤សំនួរ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងយល់អំពីការចូលរួមពិភាក្សាអំពីលទ្ធផលនៃការសិក្សារបស់កូនជាមួយនាយកសាលា គ្រូប្រចាំថ្នាក់ពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាល និងសំណូមពរ។

## ៣.៤. ដំណើរការប្រមូលទិន្នន័យ

យោងលិខិតលេខ៖ ១៨៨៥ អយក.វជអ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩របស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិតឧទ្ទេសនាម១១៩ វជអ. ផក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩របស់វិទ្យាស្ថានជាតិអប់រំស្តីពីការចាត់តាំងឱ្យចុះប្រមូលទិន្នន័យសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់និស្សិតផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅតាមរាជធានីខេត្តនានា និងចំណារអនុញ្ញាតចុះថ្ងៃទី២៨/៥/២០១៩របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ។ លិខិតឧទេសនាមនេះត្រូវបានយកទៅជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកគោលដៅទាំង៤ដើម្បីសុំការអនុញ្ញាត និងស្នើសុំទីតាំងសម្រាប់ប្រមូលទិន្នន័យនៅតាមសាលាបឋមសិក្សាចំនួន០៨។

តាមរយៈការប្រាស្រ័យសំណេះសំណាលជាមួយគ្រូប្រចាំថ្នាក់ អ្នកស្រាវជ្រាវបានទទួលព័ត៌មានអំពីប្រវត្តិរូបសង្ខេបរបស់សិស្សរៀនយឺតខ្លះៗដើម្បីងាយស្រួលក្នុងការទៅជួបជាមួយឪពុកម្តាយ ឬអាណាព្យាបាលពួកគាត់ដល់ផ្ទះក្នុងគោលបំណងស្វែងយល់ពីការចូលរួមរបស់ពួកគាត់លើការជួយកូនៗពួកគាត់ដែលរៀនយឺត។ ការជួបជាមួយឪពុកម្តាយ ឬអាណាព្យាបាលសិស្សនេះត្រូវបានធ្វើឡើងដោយប្រើវិធីចាប់យកដោយចៃដន្យដោយក្នុងមួយសាលាកំណត់យកសិស្សរៀនយឺតបួននាក់ជាតំណាងក្នុងការជួបជាមួយឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។ ដូច្នេះជាសរុបអាណាព្យាបាល៣២នាក់ត្រូវបានជួបបាន។

## ៣.៥. ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានត្រូវបានធ្វើការវិភាគយ៉ាងលម្អិតតាមកម្មវិធីSPSS ដោយប្រើឧបករណ៍វិភាគ Crosstabs ដើម្បីរកឱ្យឃើញពីកម្រិតខុសគ្នារវាងសាលាក្នុងក្រុង និងសាលាក្រៅក្រុង និង Independent Sample T-test ដើម្បីរកតម្លៃមធ្យម គម្លាតគម្រូ និងP-value នៃសកម្មភាពចូលរួមរបស់ភាគីពាក់ព័ន្ធ។ តាម Oxford និង Burry stock (1995) បានកំណត់តម្លៃ

Mean ចាប់ពី3.50 ឡើងស្ថិតក្នុងកម្រិតខ្ពស់ នៅចន្លោះ2.50ទៅ3.49 ស្ថិតក្នុងកម្រិតមធ្យម និងក្រោម2.50 ស្ថិតក្នុងកម្រិតទាប។ ជាមួយគ្នានេះដែរ កម្មវិធី Microsoft Excel ក៏ត្រូវបានប្រើប្រាស់ដើម្បីតាងក្រាប និងរកភាគរយទៅលើកម្រិតសកម្មភាពនានា និងកិច្ចគាំទ្រផ្សេងៗដែលភាគីពាក់ព័ន្ធធ្វើបានក្នុងការជួយសិស្សរៀនយឺត។

## ៣.៦. ក្រមសីលធម៌ក្នុងការស្រាវជ្រាវ

ក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវគោរពយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌របស់អ្នកស្រាវជ្រាវ ដោយបានសុំការអនុញ្ញាតិតាមលំដាប់ឋានានុក្រមតាំងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុករហូតដល់ថ្នាក់សាលាដោយយោងទៅតាមលិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងបានបង្ហាញពីគោលបំណងជាក់លាក់ក្នុងការចុះប្រមូលទិន្នន័យទៅដល់អ្នកពាក់ព័ន្ធក្នុងការសុំឱ្យពួកគាត់ចូលរួមសហការក្នុងការបំពេញកម្រងសំនួរដើម្បីឱ្យពួកគាត់មានភាពជឿជាក់ចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវ សាមគ្គីភាពធ្វើយ៉ាងណាឱ្យការស្រាវជ្រាវនេះប្រព្រឹត្តទៅដោយរលូន និងសម្រេចបានជោគជ័យ។

## ជំពូកទី ៤៖ ការវិភាគ និងចំណោកស្រាយ

ការវិភាគ និងបំណាកស្រាយត្រូវបានធ្វើឡើងបន្ទាប់ពីការប្រមូលបានទិន្នន័យតាមការគ្រោងទុកដោយផ្អែកទៅលើលទ្ធផលនៃការបំពេញកម្រងសំនួររបស់គណៈនាយកសាលា គ្រូប្រចាំថ្នាក់ក្នុងសាលាគោលដៅទាំងប្រាំបី និងតំណាងឪពុកម្ដាយ ឬអាណាព្យាបាលសិស្សរៀនយឺតទាំងសាមសិបពីររូប។

ដើម្បីឆ្លើយតបនឹងវត្ថុបំណង និងសំនួរស្រាវជ្រាវខាងលើ ការវិភាគនេះធ្វើឡើងដោយពិនិត្យមើលយ៉ាងលម្អិតលើ១១ចំនុច ដែលចំនុចទាំងនោះត្រូវបានគិតថាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការបំពេញសេវាបង្រៀន និងរៀនជាពិសេសកម្រិតនៃការជួយសិស្សរៀនយឺតនៅតាមសាលាបឋមសិក្សា។ ចំនុចទាំងនោះមាន៖

- គុណវុឌ្ឍិនាយកសាលា- គ្រូប្រចាំថ្នាក់
- មុខរបរអាណាព្យាបាលសិស្សរៀនយឺត
- ស្ថិតិសិស្សរៀនយឺតតាមថ្នាក់
- មុខវិជ្ជាដែលសិស្សរៀនយឺតជួបការលំបាក
- ការរៀបចំសកម្មភាពជួយសិស្សរៀនយឺត
- ការដាក់ និងកែកិច្ចការផ្ទះ
- ការជួយបង្រៀនកូនបន្ថែមនៅផ្ទះរបស់ឪពុម្ដាយ
- ការជួបប្រជុំរវាងនាយកសាលា និងអាណាព្យាបាលសិស្សរៀនយឺត
- ការផ្ដល់ និងការទទួលព័ត៌មានអំពីការសិក្សារបស់សិស្សរៀនយឺតរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាលសិស្សរៀនយឺត
- ការបញ្ជូន និងទទួលសៀវភៅតាមដានការសិក្សា
- បញ្ហាប្រឈម

## ៤.១. គុណវុឌ្ឍិនាយកសាលា - គ្រូប្រចាំថ្នាក់




**រូបទី១៖ គុណវុឌ្ឍិគណៈនាយកសាលា - គ្រូប្រចាំថ្នាក់**

ពិនិត្យជារួមដោយផ្អែកលើលទ្ធផលនៃ P-value=0.40 (ឧបសម្ព័ន្ធទី២ តារាងទី១) ដែលបានរកឃើញខាងលើ បង្ហាញថាកម្រិតគុណវុឌ្ឍិរបស់នាយកសាលាទាំងនៅក្នុងក្រុង និងក្រៅក្រុងមានភាពដូចគ្នា។ ប៉ុន្តែបើពិនិត្យលម្អិតដោយផ្អែកលើកម្រិតតម្លៃមធ្យមរវាងនាយកក្នុងក្រុង Mean (Urban=2.50>Rural=2.33) (ឧបសម្ព័ន្ធទី២ តារាងទី១) បង្ហាញថារបាយនៃកម្រិតគុណវុឌ្ឍិនាយកនៅក្នុងក្រុងខ្ពស់ជាងនាយកសាលានៅក្រៅក្រុង។ ម្យ៉ាងទៀតដោយផ្អែកតាមលទ្ធផលក្រាបខាងលើបង្ហាញថា មិនមាននាយកសាលាណាម្នាក់ដែលកម្រិតសិក្សារបស់គាត់នៅក្រោមសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនោះទេ នេះមានន័យថាពួកគាត់សុទ្ធតែមានកម្រិតសិក្សាដែលបំពេញបានតាមលក្ខខ័ណ្ឌនៃតម្រូវការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះទៀត នាយកសាលានៅក្នុងក្រុងពាក់កណ្ដាល និងនាយកសាលានៅក្រៅក្រុងជាងសាមសិបភាគរយទៀតដែលបានព្យាយាមអភិវឌ្ឍសមត្ថភាពរបស់ខ្លួនដោយបានបន្តការសិក្សារហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ជាមួយគ្នានេះ ចំពោះកម្រិតគុណវុឌ្ឍិរបស់គ្រូប្រចាំថ្នាក់ទាំងនៅក្នុងក្រុង និងក្រៅក្រុងដោយផ្អែកលើតម្លៃ Mean (Urban=2.25, Rural=2.17) និងតម្លៃនៃ P-value =0.47 (ឧបសម្ព័ន្ធទី២ តារាងទី១) ក៏មានការបកស្រាយប្រហាក់ប្រហែលគ្នានឹងទិន្នន័យរបស់នាយកសាលាដែរ ។ តាម Oxford និង Burry stock, (1995) ឃើញថាកម្រិតគុណវុឌ្ឍិរបស់គ្រូប្រចាំថ្នាក់នៅមានកម្រិតទាបទាំងគ្រូនៅក្នុងក្រុង និងក្រៅក្រុង (M<2.50)។

គ្រូបង្រៀនមួយចំនួនតូចទាំងនៅក្នុងក្រុង និងក្រៅក្រុងមិនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (មិនមានបាក់ឌុប) ដែលមិនទាន់បំពេញបាននូវលក្ខខ័ណ្ឌចាំបាច់របស់ក្រសួងនៅឡើយ។ ប៉ុន្តែគ្រូបង្រៀនជិតពាក់កណ្តាលទៀតដែលបានបន្តការសិក្សារបស់ខ្លួនរហូតបញ្ចប់ការសិក្សាដល់ថ្នាក់បរិញ្ញាបត្រ។ នេះបង្ហាញពីការយកចិត្តទុកដាក់របស់ពួកគាត់ក្នុងការខិតខំអភិវឌ្ឍសមត្ថភាពសិក្សារបស់ខ្លួនស្របតាមគោលនយោបាយអប់រំជាតិគឺការសិក្សាពេញមួយជីវិត និងបំពេញបាននូវតម្រូវការជាតិ និងការប្រកួតប្រជែងក្នុងតំបន់ដោយពួកគាត់យល់ថា ភាពទូលំទូលាយនៃចំណេះដឹងធ្វើឱ្យមានភាពងាយស្រួលក្នុងការបង្រៀន និងផ្ទេរចំណេះដឹងទៅសិស្សប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។

ជារួមមក យើងអាចសន្និដ្ឋានបានថាកម្រិតគុណវុឌ្ឍិរបស់គណៈនាយកសាលារៀន និងគ្រូបង្រៀនទាំងនៅក្នុងក្រុង និងក្រៅក្រុងមានកម្រិតមិនខុសគ្នានោះទេដោយពួកគាត់នៅតែព្យាយាមអភិវឌ្ឍសមត្ថភាពសិក្សារបស់ខ្លួនដើម្បីឱ្យការផ្ទេរចំណេះដឹងដល់សិស្សមានភាពងាយស្រួល និងប្រសិទ្ធភាពខ្ពស់។

## ៤.២. មុខរបរអាណាព្យាបាលសិស្សរៀនយឺត




រូបភាពទី២៖ មុខរបរអាណាព្យាបាលសិស្សរៀនយឺត

តាមក្រាបបង្ហាញថា ភាគច្រើននៃអាណាព្យាបាលសិស្សរៀនយឺតក្នុងក្រុងជាអាជីវករ គឺពួកគាត់រកស៊ីលក់ដូរនៅផ្ទះដែលអាចមានពេលវេលាច្រើនក្នុងការនៅជាមួយកូន និងងាយស្រួលក្នុងការតាមដានការសិក្សារបស់កូនជាងអាណាព្យាបាលសិស្សរៀនយឺតក្រៅក្រុងដែលភាគច្រើនជាកម្មកររោងចក្រធ្វើការពេញម៉ោងឆ្ងាយពីផ្ទះមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការ

នៅក្បែរកូន និងមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការតាមដានការសិក្សារបស់កូនឱ្យបានពេញលេញ។ ជាមួយគ្នានោះ ក៏មានអាណាព្យាបាលសិស្សរៀនយឺតតិចតួចដែរទាំងនៅក្នុងក្រុង និងក្រៅក្រុងគឺជាមន្ត្រីរាជការ និងកសិករ។ ផ្អែកលើទិន្នន័យនេះបង្ហាញថាគ្រួសារនៅក្នុងក្រុងមានលទ្ធភាពច្រើនជាងគ្រួសារនៅក្រៅក្រុងក្នុងការជួយជំរុញ និងបង្កើនកិច្ចសហការល្អជាមួយសាលារៀន ដែលជាហេតុធ្វើឱ្យការជួយកូនៗរបស់ពួកគាត់ដែលរៀនយឺតទទួលបានផលល្អជាង។

## ៤.៣. ស្ថិតិសិស្សរៀនយឺតតាមថ្នាក់




**រូបទី៣៖ ស្ថិតិសិស្សរៀនយឺតតាមថ្នាក់**

ពិនិត្យជាទូទៅតាមរយៈលទ្ធផលនៃទិន្នន័យខាងលើបង្ហាញថា គ្រប់ថ្នាក់ទាំងអស់ទាំងសាលាក្នុងក្រុង និងសាលាក្រៅក្រុងសុទ្ធតែមានសិស្សរៀនយឺតដូចគ្នា (P-value =0.10) ។ ប៉ុន្តែតាមការរៀបជាក្រុមនៃចំនួនសិស្សរៀនយឺតតាមលំដាប់ពី ១-៥នាក់ ពី៦-១០នាក់ និងចាប់ពី១០នាក់ឡើង លទ្ធផលបង្ហាញឡើងតាមរយៈក្រាប និង Mean (Urban=2,69>Rural=2.49) (ឧបសម្ព័ន្ធទី២ តារាងទី២) ឃើញថាទំហំនៃចំនួនសិស្សរៀនយឺតនៅតាមថ្នាក់នីមួយៗនៃសាលាក្នុងក្រុង និងក្រៅក្រុងមានភាពខុសគ្នាដោយចំនួនសិស្សរៀនយឺតសាលាក្នុងក្រុងមានទំហំតូចជាងសាលាក្រៅក្រុង (ក្រាបខាងលើ)។ ភាពខុសគ្នានេះដោយសារឪពុកម្តាយសិស្សក្នុងក្រុងមានពេលវេលានៅជាមួយកូនច្រើនជាងគ្រួសារក្រៅក្រុង សិស្សក្នុងក្រុងមានលទ្ធភាពច្រើនជាងក្នុងការទទួលបានសេវាសិក្សាបន្ថែមក្រៅម៉ោងសិក្សារបស់សាលារដ្ឋជាមួយគ្រូប្រចាំថ្នាក់របស់ខ្លួនជាប្រចាំ និងសាលាឯកជនខាងក្រៅ ខណៈពេលដែលសិស្សនៅក្រៅក្រុងមិនមានលទ្ធភាពទទួលបានការបង្រៀនក្រៅម៉ោងបន្ថែមពីគ្រូប្រចាំ

ថ្នាក់របស់ខ្លួន និងមានសិស្សតិចតួចដែលមានលទ្ធភាពរកសេវាអប់រំនៅសាលាឯកជនខាងក្រៅ។ ជាមួយគ្នានេះ សម្ភារសិក្សា និងទំហំនៃចំនួនសិស្សក្នុងថ្នាក់នីមួយៗជះឥទ្ធិពលខ្លាំងដល់លទ្ធផលនៃការបង្រៀន និងរៀនផងដែរ។

## ៤.៤. មុខវិជ្ជាដែលសិស្សរៀនយឺតជួបការលំបាក




**រូបទី៤៖ មុខវិជ្ជាដែលសិស្សរៀនយឺតជួបការលំបាក**

កម្រិតថ្នាក់នៅបឋមសិក្សាត្រូវបានចែកចេញជាពីរគឺកម្រិតទី១ពីថ្នាក់ទីមួយដល់ទីបីដែលមានមុខវិជ្ជាសិក្សាសំខាន់ៗបីគឺភាសាខ្មែរ គណិតវិទ្យា និងសិក្សាសង្គម កម្រិតទី២ពីថ្នាក់ទីបួនដល់ទីប្រាំមួយដែលមានមុខវិជ្ជាសិក្សាសំខាន់ៗប្រាំគឺភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម វិទ្យាសាស្ត្រ និងភាសាបរទេស។ មុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរជាមុខវិជ្ជាគោលក្នុងចំណោមមុខវិជ្ជាសិក្សាទាំងអស់នៅបឋមសិក្សាដោយមានចំនួនម៉ោងក្នុងសប្តាហ៍ច្រើនជាងគេហើយវាក៏ជះឥទ្ធពលដល់ការសិក្សាមុខវិជ្ជាដទៃទៀតដែរ។ តាមក្រាប និងលទ្ធផលនៃតម្លៃ P-value =0.43 (ឧបសម្ព័ន្ធទី២ តារាងទី៣) បង្ហាញថា សិស្សទាំងនៅក្នុងក្រុង និងក្រៅក្រុងមានការលំបាកខ្លាំងទៅលើមុខវិជ្ជាមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យានេះដូចគ្នា ដែលជាហេតុធ្វើឱ្យពួកគេជួបប្រទះនឹងបញ្ហាប្រឈមគ្រប់មុខវិជ្ជាទាំងអស់នៅក្នុងម៉ោសិក្សា។ ជាទូទៅសិស្សរៀនយឺតក្នុងកម្រិតទីមួយ (ថ្នាក់ទី១ដល់ទី៣) ជួបបញ្ហាប្រឈមខ្លាំងទៅលើមុខវិជ្ជាភាសាខ្មែរជាងគណិតវិទ្យាដោយពួកគេលំបាកក្នុងការអាន និងសរសេរពិសេសគឺមិនស្គាល់តួ

ព្យញ្ជនៈ និងស្រៈ។ ដូចនេះដើម្បីជួយពួកគេឱ្យមានប្រសិទ្ធភាពក្នុងការសិក្សានូវគ្រប់មុខវិជ្ជាទាំងអស់ចំនុចចាប់ផ្ដើមគឺត្រូវពង្រឹងលើមុខវិជ្ជាគោលទាំងពីរនេះជាមុន។

## ៤.៥. ការរៀបចំសកម្មភាពជួយសិស្សរៀនយឺត




**រូបទី៥៖ ការរៀបចំសកម្មភាពជួយសិស្សរៀនយឺត**

ការរៀបចំសកម្មភាពជួយសិស្សរៀនយឺតជាវិធីដែលត្រូវអនុវត្តជាចាំបាច់ដើម្បីរំលស់ចំនួនសិស្សរៀនយឺតតាមថ្នាក់នីមួយៗប្រកបដោយប្រសិទ្ធភាព។ សកម្មភាពទាំងនោះមានដូចជា៖

### ក. សកម្មភាពសិស្សជួយសិស្ស (ខ្លាំងជួយខ្សោយ)

ការចាត់តាំងសកម្មភាពសិស្សខ្លាំងជួយសិស្សខ្សោយអាចឱ្យសិស្សមានឱកាសបានជួយគ្នាទាំងក្នុងម៉ោងសិក្សានិងក្រៅម៉ោងសិក្សាធ្វើឱ្យពួកគេមានភាពស្និទ្ធស្នាលនិងចេះសាមគ្គីគ្នា ពិសេសគឺសិស្សរៀនយឺតហាក់មិនសូវមានអារម្មណ៍ខ្មាស់អៀន និងធ្វើឱ្យពួកគេមានភាពក្លាហានក្នុងការចូលរួមក្នុងសកម្មភាពការងារថ្នាក់រៀន ហើយក៏ជាការបំប៉នពួកគេបន្ថែមលើការជួយរបស់គ្រូផងដែរ។ ពិនិត្យទៅលើលក្ខណៈទូទៅដោយផ្អែកតាមលទ្ធផលតម្លៃ P-value =0.17 (ឧបសម្ព័ន្ធទី២ តារាងទី៤) បង្ហាញថា ទាំងគ្រូនៅក្នុងក្រុង និងក្រៅក្រុងបាន

អនុវត្តការចាត់តាំងសកម្មភាពសិស្សខ្លាំងជួយសិស្សខ្សោយនេះដូចគ្នា គឺស្ថិតក្នុងកម្រិតជាប្រចាំ និងញឹកញប់។ យោងទៅតាមលទ្ធផល Mean (Urban=3.50>Rural= 3.31) (ឧបសម្ព័ន្ធទី២ តារាងទី៤) និង តាម Oxford និង Burry stock, (1995) បង្ហាញថាគ្រូនៅក្នុងក្រុងអនុវត្តសកម្មភាពនេះបានក្នុងកម្រិតខ្ពស់ ខណៈដែលគ្រូនៅក្រៅក្រុងអនុវត្តបានក្នុងកម្រិតមធ្យម ដោយការចាត់តាំងសកម្មភាពសិស្សជួយសិស្សជាប្រចាំរបស់គ្រូក្នុងក្រុងមានភាគរយខ្ពស់ជាងគ្រូក្រៅក្រុងដោយមានរហូតដល់ជិតហុកសិបភាគរយ ខណៈពេលដែលគ្រូក្រៅក្រុងមានត្រឹមតែសែសិបភាគរយ ចំណែកកម្រិតនៃភាពញឹកញាប់របស់គ្រូក្នុងក្រុងមានជាងសាមសិបភាគរយ ខណៈគ្រូក្រៅក្រុងមានហាសិបភាគរយ (ក្រាបខាងលើ)។ នេះបង្ហាញថាគ្រូនៅក្រៅក្រុងនៅមានកម្រិតស្រាលជាងគ្រូនៅក្នុងក្រុងក្នុងការយកចិត្តទុកដាក់ចាត់តាំងសកម្មភាពសិស្សខ្លាំងជួយសិស្សខ្សោយនេះ។

### ខ. ការរៀបចំកន្លែងអង្គុយ

កន្លែងអង្គុយរបស់សិស្សជាជំនួយមួយផ្នែកពាក់ព័ន្ធនឹងបរិយាកាសសិក្សារបស់ពួកគេ ពិសេសគឺសិស្សរៀនយឺត។ការរៀបចំកន្លែងអង្គុយរបស់សិស្សឱ្យបានសមស្របតាមបច្ចេកទេសគរុកោសល្យ ពិសេសគឺសិស្សរៀនយឺតត្រូវបានរៀបចំអង្គុយតាមប្រភេទ និងដាក់ឱ្យបាននៅក្បែរសិស្សរៀនពូកែធ្វើឱ្យពួកគេមានភាពងាយស្រួលក្នុងការជួយគ្នាក្នុងម៉ោងសិក្សា។ តាមក្រាបខាងលើបង្ហាញថា គ្រូបង្រៀនទាំងអស់ទាំងនៅក្នុងក្រុង និងនៅក្រៅក្រុងសុទ្ធតែបានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំកន្លែងអង្គុយរបស់សិស្សដើម្បីបង្កភាពងាយស្រួលដល់ពួកគេក្នុងការចាប់យកខ្លឹមសារមេរៀន។

### គ. ការងារក្រុម

ការចាត់តាំងការងារក្រុមជាវិធីសាស្ត្រមួយក្នុងការជំរុញការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យមានប្រសិទ្ធភាពខ្ពស់ ពីព្រោះពួកគេមានឱកាសបានពិភាក្សាគ្នា និងបានជួយគ្នាក្នុងក្រុម ពិសេសគឺសិស្សរៀនយឺតអាចមានឱកាសក្នុងការជួយពីមិត្តភក្តិរបស់គេចំពោះកិច្ចការដែលគ្រូដាក់ឱ្យធ្វើ។ ផ្អែកទៅតាមក្រាប និងតាមលទ្ធផលនៃតម្លៃ P-value =0.00 ខាងលើបង្ហាញថាកម្រិតនៃការចាត់តាំងសកម្មភាពការងារក្រុមរបស់គ្រូនៅក្នុងក្រុងនិងគ្រូនៅក្រៅក្រុងមានភាពខុសគ្នា។ ផ្អែកតាមតម្លៃ Mean (Urban=3.63>Rural=2.71) (ឧបសម្ព័ន្ធទី២ តារាងទី៥)បង្ហាញថាគ្រូនៅក្នុងក្រុងបានចាត់តាំងការងារក្រុមសកម្មជាងគ្រូនៅក្រៅក្រុងដោយសកម្មភាពគ្រប់ម៉ោងមានភាគរយខ្ពស់ជាងគ្រូនៅក្រៅក្រុងដាច់។ កម្រិតនៃភាពញឹកញាប់មានភាគរយប្រហាក់ប្រហែលគ្នារវាងគ្រូនៅក្រៅក្រុង និងគ្រូនៅក្នុងក្រុង ខណៈដែលកម្រិតម្តង

ម្តាលគ្រូនៅក្រៅក្រុងមានភាគរយខ្ពស់ជាងគ្រូក្នុងក្រុងដាច់។ នេះបង្ហាញពីកម្រិតខុសគ្នាក្នុងការយកចិត្តទុកដាក់អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរវាងគ្រូក្នុងក្រុង និងគ្រូនៅក្រៅក្រុងដែលវាបង្ហាញអំពីប្រសិទ្ធភាពនៃការជួយសិស្សរៀនយឺតទៅតាមកម្រិតសកម្មភាពនីមួយៗ។

### ឃ. ការហៅសិស្សរៀនឡើងឆ្លើយសំនួរ និងឡើងក្តារខៀន

តាមក្រាប និងតាមលត្ធផលនៃតម្លៃ P-value =0.17 (ឧបសម្ព័ន្ធទី២ តារាងទី៦) ខាងលើបង្ហាញថាគ្រូបង្រៀនទាំងនៅក្នុងក្រុង និងក្រៅក្រុងបានហៅសិស្សរៀនយឺតឆ្លើយសំនួរ ឬឡើងក្តារខៀនក្នុងកម្រិតដូចគ្នាគឺស្ថិតក្នុងកម្រិតរៀងរាល់ម៉ោង និងញឹកញាប់។ ផ្អែកលើតម្លៃ Mean (Urban= 3.44>Rural=3.29) (ឧបសម្ព័ន្ធទី២ តារាងទី៦) អាចសន្និដ្ឋានបានថាគ្រូនៅក្នុងក្រុងមានការអនុវត្តវិធីនេះបានល្អជាងគ្រូនៅក្រៅក្រុង។ ការអនុវត្តសកម្មភាពនេះវាហាក់មានការលំបាកច្រើនចំពោះសាលាក្រៅក្រុងដោយសារចំនួនសិស្សមានច្រើន និងទំហំសិស្សរៀនយឺតក្នុងថ្នាក់មានចំនួនច្រើនជាងសាលាក្នុងក្រុងដូចនេះការហៅមិនអាចធ្វើបានគ្រប់គ្នា និងគ្រប់ម៉ោងនោះទេ។ ឆ្លងតាមទិន្នន័យនេះនៅតែបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់ពួកគាត់ក្នុងការព្យាយាមកាត់បន្ថយអត្រាសិស្សរៀនយឺតនៅក្នុងថ្នាក់របស់ខ្លួនរៀងៗខ្លួន។

និយាយជារួមសកម្មភាពក្នុងថ្នាក់ទាំងបួនខាងលើមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការបំពេញសេវាបង្រៀនស្របតាមគោលវិធីសិស្សមជ្ឈមណ្ឌល និងជាពិសេសគឺការជួយសិស្សរៀនយឺតដែលបង្កលក្ខណៈងាយស្រួលដល់ពួកគេក្នុងការចាប់យកខ្លឹមសារមេរៀន។

## ៤.៦. ការដាក់ និងកែកិច្ចការផ្ទះ




**រូបទី៦៖ ការដាក់ និងការកែកិច្ចការផ្ទះ**

ការដាក់កិច្ចការផ្ទះជាប្រចាំឱ្យសិស្សធ្វើក្នុងគោលបំណងឱ្យសិស្សបានអនុវត្តន៍ឡើងវិញនូវអ្វីដែលគេទើបតែបានរៀននៅសាលាថ្មីៗជាការរំលឹក និងជួយពួកគេឱ្យចងចាំ និងយល់បានកាន់តែល្អនូវខ្លឹមសារមេរៀនពីសាលា។ ការកែនូវគ្រប់កិច្ចការផ្ទះដែលបានដាក់ឱ្យពួកគេធ្វើជាប្រចាំជាការលើទឹកចិត្តពួកគេឱ្យខិតខំប្រឹងប្រែងធ្វើនូវរាល់កិច្ចការដែលគ្រូដាក់ឱ្យពួកគេពីសាលាកាន់តែខ្លាំង។ តាមលទ្ធផលនៃទិន្នន័យខាងលើដោយផ្អែកលើលទ្ធផលក្រាប តម្លៃនៃ P-value និង Mean (ឧបសម្ព័ន្ធទី២ តារាងទី៧) ឃើញថាលោកគ្រូ អ្នកគ្រូទាំងសាលាក្នុងក្រុង និងក្រៅក្រុងបានដាក់ និងកែគ្រប់កិច្ចការផ្ទះរបស់សិស្សដូចគ្នា។ នេះបង្ហាញពីស្មារតីនៃការទទួលខុសត្រូវក្នុងកាតព្វកិច្ចជាគ្រូបង្រៀន និងការយកចិត្តទុកដាក់ខ្ពស់របស់ពួកគាត់ចំពោះកិច្ចការផ្ទះរបស់សិស្ស។ ការកែកិច្ចការផ្ទះ និងការបង្ហាញពីចំណុចខ្វះខាតរបស់គេជាការពង្រឹងពុទ្ធិរបស់គេឡើងវិញព្រមទាំងជួយឱ្យពួកគេកាន់តែយល់ច្បាស់បន្ថែមទៀតនូវអ្វីដែលពួកគេមានភាពស្រពិចស្រពិល ពិសេសគឺសិស្សរៀនយឺតដោយបានជួយពួកគេឱ្យយល់ច្បាស់បន្ថែមទៀតនូវខ្លឹមសារមេរៀន។

### ៤.៧. ការជួយបង្រៀនកូនបន្ថែមនៅផ្ទះ




**រូបទី៧៖ ការជួយបង្រៀនកូនបន្ថែមនៅផ្ទះរបស់អាណាព្យាបាល**

ការពិនិត្យតាមដានទៅលើសៀវភៅសិក្សារបស់កូន និងការជួយបង្រៀនកូនបន្ថែមនៅផ្ទះជាប្រចាំជារៀងរាល់ថ្ងៃរបស់អាណាព្យាបាលសិស្សជាការចូលរួមយ៉ាងសំខាន់ក្នុងការជួយឱ្យការសិក្សារបស់កូនទទួលបានលទ្ធផលល្អ និងជាការលើកទឹកចិត្តកូនឱ្យមានទំនុកចិត្តទៅលើការសិក្សាវាអាចជួយឱ្យកូនបានយល់នូវអ្វីដែលគេយល់ពុំសូវច្បាស់នៅសាលា និងចងចាំ

ឡើងវិញនូវអ្វីដែលពួកគេភ្លេចក្រោយពីការបង្រៀនរបស់គ្រូ ពិសេសគឺសិស្សរៀនយឺតដែលត្រូវការការជួយជាពិសេសពីគ្រូបង្រៀន និងឪពុកម្តាយ។ តាមតម្លៃ P-value =0.17 ខាងលើបង្ហាញថាកម្រិតនៃការយកចិត្តទុកដាក់ជួយបង្រៀនកូនបន្ថែមនៅផ្ទះរបស់ឪពុកម្តាយសិស្សរៀនយឺតទាំងនៅក្នុងក្រុង និងក្រៅក្រុងមិនមានភាពខុសគ្នានោះទេ ។ ប៉ុន្តែបើពិនិត្យលម្អិតតាមតម្លៃ Mean (Urban=2.13>Rural=1.79) (ឧបសម្ព័ន្ធទី២ តារាងទី៨) និងតាមក្រាបខាងលើបង្ហាញថាអាណាព្យាបាលសិស្សរៀនយឺតនៅក្នុងក្រុងយកចិត្តទុកដាក់ខ្ពស់ជាងអាណាព្យាបាលសិស្សរៀនយឺតនៅក្រៅក្រុងក្នុងការជួយបង្រៀនកូនបន្ថែមនៅផ្ទះដែលកម្រិតនៃភាពញឹកញាប់មានភាគរយខ្ពស់រហូតដល់ហុកសិភាគរយ និងម្តងម្កាលមានតែជាងសាមសិបភាគរយ និងមិនដែលសោះមានសូន្យភាគរយ។ ចំណែកឯអាណាព្យាបាលសិស្សនៅក្រៅក្រុងមានតែជាងដប់ភាគរយប៉ុណ្ណោះដែលបានបង្រៀនកូនញឹកញាប់ ជាងសាមសិបភាគរយបង្រៀនម្តងម្កាល និងជិតសែសិបភាគរយមិនដែលបង្រៀនសោះ។ ផ្អែកលើលទ្ធផលនេះ និងយោងតាម Oxford and Burry-Stock, (1995)ការជួយបង្រៀនកូនបន្ថែមនៅផ្ទះរបស់អាណាព្យាបាលសិស្សរៀនយឺតទាំងនៅក្នុងក្រុង និងក្រៅក្រុងស្ថិតក្នុងកម្រិតទាប។ ដូចនេះបង្ហាញថាកម្រិតនៃការយកចិត្តទុកដាក់របស់ពួកគាត់ចំពោះការសិក្សារបស់កូននៅមានកម្រិតដោយពួកគាត់មានចំនុចឆកល្វែងច្រើនពុំបានជួយបង្រៀនកូនជាប្រចាំ និងជារៀងរាល់ថ្ងៃ។ តាមការចុះជួបផ្ទាល់នឹងអាណាព្យាបាលសិស្សរៀនយឺត និងទិន្នន័យដែលទទួលបានតាមការបំពេញកម្រងសំណួរភាគច្រើននៃអាណាព្យាបាលសិស្សរៀនយឺតក្នុងក្រុងជាអាជីវកររកស៊ីនៅផ្ទះផ្ទាល់ខ្លួនមានកម្រិតជីវភាពធូរធាជាង និងមានពេលវេលាច្រើនជាងក្នុងការនៅជាមួយកូន និងមើលថែកូន។ ចំណែកឪពុកម្តាយសិស្សរៀនយឺតក្រៅក្រុងវិញភាគច្រើនជាកសិករ និង ជាអ្នកធ្វើការរោងចក្រដែលមិនមានពេលវេលាគ្រប់គ្រាន់បាននៅក្បែរកូនជាប្រចាំរាល់ថ្ងៃ។ ដូច្នេះកម្រិតនៃការយកចិត្តទុកដាក់របស់អាណាព្យាបាលសិស្សនៅក្រៅក្រុងចំពោះការសិក្សារបស់កូនមានភាពកំសោយជាងអាណាព្យាបាលនៅក្នុងក្រុង។

## ៤.៨. ការទំនាក់ទំនងរវាងសាលារៀន និងអាណាព្យាបាលសិស្សរៀនយឺត

### ៤.៨.១. ការជួបប្រជុំរវាងនាយកសាលា និងអាណាព្យាបាលសិស្សរៀនយឺត




**រូបទី៨៖ ការប្រជុំពិភាក្សារវាងនាយកសាលា និងអាណាព្យាបាលសិស្សរៀនយឺត**

ការជួបពិភាក្សាគ្នាជាប្រចាំនៃភាគីពាក់ព័ន្ធក្នុងការតាមដានទៅលើលទ្ធផលនៃការសិក្សារបស់សិស្សរៀនយឺតជាចលករដ៏សំខាន់ក្នុងការជួយជំរុញល្បឿនសិក្សារបស់ពួកគេឱ្យមានការវិវត្តទៅមុខ។ តាមក្រាប និងតាមតម្លៃ Mean (ឧបសម្ព័ន្ធទី២ តារាងទី៩) ព័ត៌មានដែលទទួលបានពីនាយកសាលា និងព័ត៌មានដែលទទួលបានពីអាណាព្យាបាលសិស្សរៀនយឺតទាក់ទងនឹងការជួបពិភាក្សាគ្នាទៅលើលទ្ធផលសិក្សារបស់សិស្សរៀនយឺតនោះមានភាពខុសគ្នាទាំងស្រុងទាំងអាណាព្យាបាលសិស្សក្នុងក្រុង និងអាណាព្យាបាលសិស្សក្រៅក្រុងដោយព័ត៌មានពីនាយកសាលាក្នុងក្រុងកម្រិតនៃការជួបគ្នាញឹកញាប់ និងម្ដងម្កាលមានភាគរយដូចគ្នា ប៉ុន្តែព័ត៌មានពីអាព្យាបាលសិស្សរៀនយឺតក្នុងក្រុងវិញគឺការជួបគ្នាក្នុងកម្រិតញឹកញាប់មានភាគរយទាបបំផុត និងមិនដែលសោះមានភាគរយខ្ពស់ដាច់។ តាមតម្លៃ Mean ដែលបានរកឃើញ (M <2.50) (ឧបសម្ព័ន្ធទី២ តារាងទី៩) បង្ហាញថាកម្រិតនៃការទំនាក់ទំនងរវាងនាយកសាលារៀន និងអាណាព្យាបាលសិស្សរៀនយឺតនៅមានកម្រិតទាប។ សាលាក្រៅក្រុងព័ត៌មានពីនាយកសាលាទាក់ទងនឹងការជួបគ្នារៀងរាល់ខែ និងមិនដែលសោះមានភាគរយប្រហាក់ប្រហែលគ្នាហើយការជួបក្នុងកម្រិតញឹកញាប់ និងម្ដងម្កាលក៏មានភាគរយប្រហាក់

ប្រហែលគ្នាដែរ ប៉ុន្តែនៅតែផ្ទុយនឹងចម្លើយរបស់អាណាព្យាបាលសិស្សរៀនយឺតដែលកម្រិតនៃការមិនដែលជួបសោះមានភាគរយខ្ពស់បំផុតដែលនេះបង្ហាញពីកម្រិតនៃការទំនាក់ទំនងរវាងនាយកសាលារៀន និងមាតាបិតាសិស្សនៅមានកម្រិតទាប ហើយវាបានឆ្លុះបញ្ចាំងមួយផ្នែកពីប្រសិទ្ធភាពនៃការជួយសិស្សរៀនយឺតផងដែរ។

### ៤.៨.២.ការផ្តល់ និងការទទួលព័ត៌មានអំពីការសិក្សារបស់សិស្សរៀនយឺតរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាល




**រូបទី៩៖ ការផ្តល់ និងការទទួលព័ត៌មានអំពីការសិក្សារបស់សិស្សរៀនយឺតរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាល**

ការផ្តល់ព័ត៌មានពីការសិក្សារបស់សិស្សទៅអាណាព្យាបាលរបស់គេពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការតាមដាន និងរួមគ្នាជួយដល់ពួកគេលើចំណុចខ្វះខាតនៃការសិក្សារបស់គេ។ ពិនិត្យលើតម្លៃ P-value =0,003 លើទិន្នន័យបានពីគ្រូប្រចាំថ្នាក់បង្ហាញថា ការផ្តល់ព័ត៌មានអំពីការសិក្សារបស់សិស្សរៀនយឺតទៅអាណាព្យាបាលរបស់គេរវាងគ្រូក្នុងក្រុង និងក្រៅក្រុងមានភាពខុសគ្នា។ ផ្អែកលើលទ្ធផលនៃតម្លៃ Mean (Urban=3.56> Rural=2.94) (ឧបសម្ព័ន្ធទី២ តារាងទី១០) និងតាមក្រាបខាងលើបង្ហាញថាកម្រិតនៃការផ្តល់ព័ត៌មានទៅអាណាព្យាបាលសិស្សរៀនយឺតរបស់គ្រូប្រចាំថ្នាក់នៅក្នុងក្រុងមានភាពសកម្មជាងគ្រូក្រៅក្រុង ដោយគ្រូក្នុងក្រុងស្ថិតក្នុងកម្រិតខ្ពស់ និងគ្រូនៅក្រៅក្រុងស្ថិតក្នុងកម្រិតមធ្យម។

ពិនិត្យលើតម្លៃ P-value =0.27 លើទិន្នន័យពីអាណាព្យាបាលសិស្សស្តីពីការទទួលព័ត៌មានពីគ្រូប្រចាំថ្នាក់មានភាពដូចគ្នា។ ផ្អែកលើតម្លៃ Mean (Urban=2.25> Rural=2.38) (ឧបសម្ព័ន្ធទី២ តារាងទី១០) និងតាមក្រាបខាងលើបង្ហាញថា អាណាព្យាបាលសិស្សរៀនយឺតនៅក្រៅក្រុងបានទទួលព័ត៌មានពីការសិក្សារបស់កូនពួកគាត់ញឹកញាប់ជាងអាណាព្យាបាលសិស្សរៀនយឺតក្នុងក្រុង។

ប្រៀបធៀបកម្រិតលម្អៀងនៃការផ្តល់ចម្លើយរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាលសិស្សឃើញថា ព័ត៌មានរវាងគ្រូ និងអាណាព្យាបាលសិស្សនៅក្នុងក្រុងមានភាពបញ្ច្រាសគ្នាខ្លាំងជាងព័ត៌មានរវាងគ្រូ និងអាណាព្យាបាលសិស្សនៅក្រៅក្រុងរវាងភាគីអ្នកផ្តល់ និងភាគីអ្នកទទួលចំពោះខ្លឹមសាររឿងតែមួយ។ នេះអាចសន្និដ្ឋានបានថា ការទំនាក់ទំនងរវាងគ្រូប្រចាំថ្នាក់ និងអាណាព្យាបាលសិស្សរៀនយឺតនៅមានកម្រិតទាបនៅឡើយដែលវានៅតែជាបញ្ហាប្រឈមមួយក្នុងការជួយសិស្សរៀនយឺតទាំងនៅក្នុងក្រុង និងក្រៅក្រុង។

### ៤.៨.៣. ការបញ្ជូន និងការទទួលសៀវភៅតាមដានការសិក្សា




**រូបទី១០៖ ការបញ្ជូន និងការទទួលសៀវភៅតាមដានការសិក្សា**

ផ្អែកតាមលទ្ធផលខាងលើពាក់ព័ន្ធនឹងការផ្ញើ និងបញ្ជូនសៀវភៅតាមដានការសិក្សាទៅអាណាព្យាបាលសិស្សនេះការអនុវត្តរបស់នាយកសាលាទាំងនៅក្នុងក្រុង និងក្រៅក្រុងដូចគ្នា។ ចំណែកលទ្ធផលនៃការផ្តល់ចម្លើយរបស់គ្រូប្រចាំថ្នាក់ស្តីពីការអនុវត្តរបស់ខ្លួនលើការផ្ញើ និងបញ្ជូនសៀវភៅតាមដានការសិក្សាសិស្សនេះមានភាពខុសគ្នារវាងគ្រូក្នុងក្រុង និងក្រៅ

ក្រុង P-value =0.002 និង Mean (Urban=3.63>Rural=2.49) (ឧបសម្ព័ន្ធទី២ តារាងទី១១) ។ នេះបង្ហាញថាគ្រូនៅក្នុងក្រុងអនុវត្តបានល្អជាងគ្រូនៅក្រៅក្រុង ដោយភាគរយនៃការបញ្ជូនរៀងរាល់ខែរបស់គ្រូក្នុងក្រុងខ្ពស់ជាងគ្រូក្រៅក្រុង និងភាគរយមិនដែលសោះរបស់គ្រូក្រៅក្រុងខ្ពស់ជាងគ្រូក្នុងក្រុង។ ប៉ុន្តែបើធ្វើការផ្ទឹមរវាងលទ្ធផលនៃការផ្តល់ចំលើយរបស់នាយកសាលា និងគ្រូប្រចាំថ្នាក់ទៅនឹងចំលើយរបស់អាណាព្យាបាលសិស្សរៀនឃើតវិញគឺខុសគ្នាទាំងស្រុងចំពោះភាគរយនៃការទទួលបានរៀងរាល់ខែគឺសូន្យ។ ផ្អែកលើលទ្ធផលនៃការផ្តល់ចំលើយរបស់អាណាព្យាបាលសិស្សរៀនឃើតនៅក្នុងក្រុង និងក្រៅក្រុងពាក់ព័ន្ធនឹងការទទួលបានសៀវភៅតាមដានការសិក្សាមានភាពខុសគ្នាដោយអ្នកនៅក្នុងក្រុងទទួលបានញឹកញាប់ជាងអ្នកនៅក្រុង P-value =0.00) និង Mean (Urban=2.63> Rural=1.33) (ឧបសម្ព័ន្ធទី២ តារាងទី១១)។ ពិនិត្យមើលជារួមឃើញថានៅតែមានភាពខុសគ្នារវាងចំលើយរបស់ភាគីអ្នកផ្តល់ និងភាគីអ្នកទទួលនៅក្នុងខ្លឹមសាររឿងតែមួយដូចទៅនឹងការផ្តល់ព័ត៌មានក្នុងចំនុច ខ ខាងលើដែរ ដែលវាបង្ហាញពីកម្រិតនៃការទំនាក់ទំនងរវាងសាលារៀន និងអាណាព្យាបាលសិស្សនៅមានកម្រិតទាបដែលមិនទាន់ឆ្លើយតបនឹងតម្រូវការចាំបាច់នៃការចង់បាន។

## ៤.៨. បញ្ហាប្រឈម

| បញ្ហាប្រឈម | | |
|---|---|---|
| ព័ត៌មានពីនាយកសាលា | កត្តាគ្រួសារ | ឪពុកម្តាយមិនសូវយល់ពីតម្លៃនៃការសិក្សារបស់កូន ខ្វះទំនាក់ទំនងល្អជាមួយសាលារៀន |
| | | ឪពុកម្តាយក្រីក្រ ផ្លាស់ទីលំនៅញឹកញាប់ |
| | | ឪពុកម្តាយចំណាកស្រុកកូននៅជាមួយយាយតា |
| | កត្តាគ្រូបង្រៀន | គ្រូបង្រៀនមួយចំនួនមិនបានប្រឹងអស់លទ្ធភាពក្នុងការបង្រៀន ខ្វះខ្វាយពេលវេលា |
| | | មិនបានធ្វើបច្ចុប្បន្នភាពកិច្ចតែងការបង្រៀន (ប្រើកិច្ចតែងការចាស់) |
| | | មិនមានសម្ភារៈបង្រៀនគ្រប់គ្រាន់ |
| | កត្តាសិស្ស | សិស្សអវត្តមានច្រើន |
| | | សិស្សគេចសាលា |
| | | សមត្ថភាពនៃការចងចាំខ្សោយ |

| | | |
|---|---|---|
| ពីគ្រូប្រចាំថ្នាក់ | កត្តាគ្រួសារ | ឪពុកម្ដាយក្រីក្រ ផ្លាស់ទីលំនៅ និងចំណាកស្រុក |
| | | អាណាព្យាបាលមិនសូវយកចិត្តទុកដាក់នឹងការសិក្សារបស់កូន មិនជួយបង្រៀនកូនបន្ថែមនៅផ្ទះ ខ្វះកិច្ចសហការជាមួយគ្រូ |
| | | អំពើហិង្សាក្នុងគ្រួសារ |
| | កត្តាសិស្ស | មិនមានសម្ភារសិក្សាគ្រប់គ្រាន់ មិនសូវធ្វើកិច្ចការផ្ទះ |
| | | សិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រក្នុងម៉ោងរៀន សិស្សអវត្តមានច្រើន |
| | | សុខភាពខ្សោយ ឈឺញឹក ពិការ |
| | | សមត្ថភាពចងចាំខ្សោយ |
| | | មិនមានគ្រឹះពីថ្នាក់ក្រោម(ខ្សោយព្យញ្ជនៈ ស្រៈ) |
| | | នៅផ្ទះលេងទូរសព្ទ មើលទូរទស្សន៍ |
| | | អៀនច្រើនមិនហ៊ានឡើងអាន ខ្លាចគ្រូ |
| | កត្តាសាលា | សិស្សក្នុងថ្នាក់ច្រើនពេក |
| | | មិនមានសម្ភារសិក្សាគ្រប់គ្រាន់ |
| | | ការផ្ដល់ព័ត៌មានទៅឪពុកម្ដាយពីអវត្តមានសិស្សនៅមានកម្រិត |

ផ្អែកលើព័ត៌មានដែលទទួលបានពីនាយកសាលា និងពីគ្រូប្រចាំថ្នាក់នៅក្នុងតារាងខាងលើបង្ហាញថាមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយដូចជា ការលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងសកម្មភាពសិក្សាដោយបង្កើតបរិយាកាសសិក្សាក្នុងថ្នាក់មួយដែលអាចជួយពង្រឹងបំរុងប្រយ័ត្នសិស្សក្នុងម៉ោងសិក្សា ពង្រឹងមូលដ្ឋានគ្រឹះមុខវិជ្ជាភាសាខ្មែរ (ព្យញ្ជនៈ ស្រៈ និងការរៀនប្រកប) ភាពក្រីក្រ និងការចូលរួមពីអាណាព្យាបាលក្នុងការទប់ស្កាត់ពួកគេពីការចំណាយពេលឥតប្រយោជន៍ក្នុងការមើលទូរទស្សន៍ ឬលេងទូរសព្ទជាដើម។ ប៉ុន្តែបញ្ហាប្រឈមខ្លាំងដែលត្រូវយកចិត្តទុកដាក់ដោះស្រាយបន្ទាន់ក្នុងការជួយសិស្សរៀនយឺតគឺកត្តាអវត្តមានសិស្ស កង្វះទំនាក់ទំនងល្អជាមួយសាលារៀន និងការមិនសូវយល់ពីតម្លៃនៃការសិក្សារបស់កូនពីសំណាក់ឪពុកម្ដាយ ឬអាណាព្យាបាលសិស្សរៀនយឺត សមត្ថភាពចងចាំរបស់សិស្សផ្ទាល់ខ្សោយ ការមិនបានតាមដានការសិក្សារបស់កូន និងការមិនបានជួយបង្រៀនកូនបន្ថែមនៅផ្ទះជាប្រចាំបូករួមនឹងគ្រូបង្រៀនមួយចំនួនមិនបានប្រឹងអស់ពីលទ្ធភាពក្នុងការជួយពួកគេ និងខ្វះខ្នាយពេលម៉ោងបង្រៀន។ ដើម្បីដោះស្រាយបញ្ហាទាំងនេះបានដោយប្រសិទ្ធភាពទាមទារចាំបាច់នូវការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធមានសាលារៀន សហគមន៍ និងឪពុកម្ដាយ ឬអាណាព្យាបាលសិស្សជាដើម។ ការបង្កើតបរិស្ថានសិក្សាមួយប្រកបដោយ

ការទាក់ទាញទាំងនៅក្នុងសាលារៀនទាំងនៅក្នុងផ្ទះ ការបង្កើនទំនាក់ទំនងល្អរវាងសាលារៀន និងអាណាព្យាបាលសិស្សរៀនឃើតជាការរួមចំណែកក្នុងការទប់ស្កាត់បញ្ហាអវត្តមានរបស់ពួកគេ ធ្វើឱ្យពួកគេមានចិត្តចង់រៀន និងក្លាហានក្នុងការចូលរួមក្នុងសកម្មភាពសិក្សា។

# ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ

## ៥.១. សន្និដ្ឋាន

សិស្សរៀនយឺតមិនមែនជាប្រភេទសិស្សដែលខួរក្បាលរបស់គេមិនមានលទ្ធភាពចាប់បាននូវខ្លឹមសារមេរៀនទាំងស្រុងទាល់តែសោះនោះទេ។ ពួកគេនៅតែអាចទទួលយកបាននូវខ្លឹមសារមេរៀនក្នុងថ្នាក់ដែលគ្រូបានបង្រៀនដោយគ្រាន់តែពួកគេត្រូវការការលើកទឹកចិត្តជាជាងការស្តីបន្ទោស ត្រូវការពេលវេលាច្រើនជាងសិស្សដទៃ ត្រូវការការជួយជាពិសេសជាងសិស្សដទៃ ត្រូវការឱ្យគ្រូថាឡើងវិញច្រើនដងនូវចំនុចនៃមេរៀននោះជាដើម ។ ពួកគេងាយប្រឈមនឹងការបោះបង់ការសិក្សាប្រសិនបើពួកគេមិនបានទទួលការយកចិត្តទុកដាក់ជាពិសេសតាមរយៈកិច្ចគាំទ្រពីសាលារៀន មិត្តភក្តិ សហគមន៍ និងអាណាព្យាបាលជាដើម។

